# អ្នកនាំសារ the messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

ខែ មិថុនា | ឆ្នាំ ២០២០ | លេខទី ១២៨

www.catholiccambodia.org/km/ | www.facebook.com/RVAKHMER/ | www.khmer.rvasia.org/

May, 2020 | #128


## វិនិយោគិន៖ «ជន្លេនក៏មានតម្លៃនិងតួនាទីផ្នែកសេដ្ឋកិច្ចសំខាន់មួយដែរ»

ទំព័រ > ៨





# គណៈប្រតិភូព្រះសហគមន៍កាតូលិក ចូលជួបសម្តែងការគួរសមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

ទំព័រ > ១៤-១៥

# ការគោរពច្បាប់ចរាចរណ៍ផ្លូវគោក ជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប

*ដោយ ៖ លី សុវណ្ណា*

សព្វថ្ងៃនេះការអនុវត្តការផាកពិន័យអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក តាមស្មារតីអនុក្រឹត្យលេខ៣៩ គឺកំពុងតែអនុវត្ត បានបន្ធូរស្ថានការណ៍ និងទុកឱកាសមួយចំនួនសម្រាប់ប្រជាពលរដ្ឋ ដើម្បីរៀបចំឱ្យមានឯកសារសម្គាល់យានយន្ត ប័ណ្ណបើកបរ ដោយរួមមានទាំងការត្រួតពិនិត្យបច្ចេកទេស (ឆៀក) រថយន្ត និង ... ប៉ុន្តែការផ្អាកដាក់កន្លែងត្រួតពិនិត្យមានមែន តែបើមានបទល្មើសចរាចរការផាកពិន័យនឹងអនុវត្តដដែល។




ក្នុងអំឡុងពេលនៃការរឹតបន្តឹងនេះ ប្រជាពលរដ្ឋភ្ញាក់រឭក ហើយនាំគ្នាសម្រុកទៅត្រួតពិនិត្យបច្ចេកទេសយានយន្ត (ឆៀក) ក៏ដូចជាទៅប្រឡងយកប័ណ្ណបើកបរក៏ដូចជាកែសម្រួល ឯកសារមួយចំនួន បង្កឱ្យមានមនុស្សច្រើនណែនណាន់តាន់តាប់។ ប្រការនេះហើយ ទើបរដ្ឋាភិបាលសម្រេចផ្អាកនិងពន្យាពេលមួយរយៈ ដើម្បីទុកឱកាសជូនបងប្អូនបំពេញកាតព្វកិច្ចទាំងនោះ។

ការអនុវត្តរឹតបន្តឹងច្បាប់ ស្របពេលដែលជំងឺឆ្លងដោយមេរោគកូវីដ១៩ កំពុងផ្ទុះឡើងផងនោះ បានធ្វើឱ្យ ពលរដ្ឋមួយចំនួន មិនសប្បាយចិត្ត ចេញមតិជំទាស់។ ជាមួយគ្នាក៏មានប្រជាពលរដ្ឋមួយចំនួនបានគាំទ្រចំពោះការអនុវត្តច្បាប់ចរាចរណ៍នេះគឺ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេស ដែលជា មធ្យមរបាយការណ៍បានអះអាងថា មានមនុស្សប្រមាណជា៥នាក់បាន បាត់បង់ជីវិតជារៀងរាល់ថ្ងៃ។

តាំងតែពីសមត្ថកិច្ចប្រកាសឱ្យគោរពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក តាមស្មារតីអនុក្រឹត្យលេខ៣៩ នៅថ្ងៃទី ១ ខែឧសភា មកដល់ពេលនេះ គឺមានសភាពល្អប្រសើរបន្តិច ដែលបានជួយឱ្យពលរដ្ឋយើងខ្លះខិតខំយកចិត្តទុកដាក់ចំពោះបច្ចេកទេសយានយន្ត ប័ណ្ណសំគាល់យានយន្ត និងប័ណ្ណបើកបរជាដើម។

*អ្នកនាំសារ* សូមទទូចឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមដោយសុទិដ្ឋិនិយមក្នុងការអនុវត្តនូវច្បាប់នេះ ដោយសង្ឃឹមថាទាំងសមត្ថកិច្ច និងបងប្អូនប្រជាពលរដ្ឋនឹងរួមគ្នាធ្វើយ៉ាងណាកាត់បន្ថយអត្រាគ្រោះថ្នាក់នៅលើទ្រូងផ្លូវនេះឱ្យបាន។

តាមរបាយការណ៍របស់សមត្ថកិច្ច លទ្ធផលនៃការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកតាមស្មារតីអនុក្រឹត្យលេខ៣៩ រយៈពេល១ខែដំបូង ចាប់ពីថ្ងៃទី០១ដល់ថ្ងៃទី៣១ខែឧសភាឆ្នាំ២០២០ បង្ហាញថា សមត្ថកិច្ចនគរបាលចរាចរណ៍ផ្លូវគោកបានត្រួតពិនិត្យនិងផាកពិន័យចំពោះយានយន្តល្មើសច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកសរុបចំនួន៤៤.៧៦៥ករណី ក្នុងនោះមានទោចក្រយានយន្តនិងត្រីចក្រយានយន្តចំនួន៣២.៧២៦ករណីស្មើនឹង៧៣% និងរថយន្តគ្រប់ប្រភេទចំនួន១២.០៣៩ករណីស្មើនឹង២៧%។

បើប្រៀបធៀបរយៈពេលដូចគ្នានៃខែឧសភាឆ្នាំ២០១៩ឃើញថា ស្ថានភាពចរាចរណ៍មានភាពល្អប្រសើរជាងមុន ដោយគ្រោះថ្នាក់ចរាចរណ៍បានថយចុះចំនួន១៣០លើកស្មើ៣៧% (២១៨/៣៤៨លើក) អ្នកស្លាប់ថយចុះ៤២នាក់ស្មើ២៧% (១១៣/១៥៥នាក់) អ្នករបួសថយចុះ១៦២នាក់ស្មើ៣២% (៣៤២/៥០៤នាក់)។ ប៉ុន្តែបើប្រៀបធៀបទៅនឹងខែមេសាឆ្នាំ២០២០នេះ គ្រោះថ្នាក់ចរាចរណ៍ថយចុះ២៨លើកស្មើ១១% (២១៨/២៤៦លើក) អ្នកស្លាប់ថយចុះ១៤នាក់ស្មើ១១% (១១៣/១២៧នាក់) អ្នករបួសថយចុះ២៦នាក់ស្មើ៧% (៣៤២/៣៦៨នាក់)។

ហើយក្នុងរយៈពេល១៥ថ្ងៃចុងក្រោយនេះ ចាប់ពីថ្ងៃ១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក រកឃើញមធ្យោបាយល្មើសសរុបចំនួន ១៧.៦៦០គ្រឿង ក្នុងនោះមានម៉ូតូចំនួន ១៣.៣១៩គ្រឿង ត្រូវបានផាកពិន័យតាមអនុក្រឹត្យលេខ៣៩ អនក្រ.បក នៅទូទាំងប្រទេស។ ចំពោះថវិកាដែលបានពីការផាកពិន័យ គឺចំនួន៧០ភាគរយប្រគល់ទៅនគរបាលដែលអនុវត្តន៍ច្បាប់ ២៥ភាគរយដាក់ទៅអង្គភាពនគរបាល និង ៥ភាគរយដាក់ចូលក្នុងថវិកាជាតិ។

ទិន្នន័យទាំងនេះបានបញ្ជាក់ថា ការគោរពច្បាប់ចរាចរណ៍ផ្លូវគោករបស់បងប្អូនប្រជាពលរដ្ឋ នៅមានកម្រិត។ កន្លងមកបងប្អូនបានជ្រាប និងបានឃើញផ្ទាល់នឹងភ្នែក ហើយ អំពីការកកស្ទះនៅលើផ្លូវនិងគ្រោះថ្នាក់នានាបង្កឡើងដោយការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដូចជា បើកបរមិនគោរពភ្លើងសញ្ញា គំនូសសញ្ញា ស្លាកសញ្ញា លើសល្បឿនកំណត់ បើកបរស្រវឹង ...។ល។

ជាការពិត ការអនុវត្តន៍ និងការគោរពច្បាប់ជាកាតព្វកិច្ចរបស់យើងម្នាក់ៗជាពលរដ្ឋ ដែលរស់នៅក្នុងប្រទេសមួយដែលជានីតិរដ្ឋ។ ការគោរពច្បាប់ចរាចរណ៍ផ្លូវគោក គឺជាការគោរពជីវិតមនុស្សលើដងផ្លូវ។ ជាមួយគ្នានេះ ក៏ជាជ្រុងមួយនៃការកាត់បន្ថយអំពើពុករលួយនៃការផាកពិន័យរបស់មន្ត្រីនគរបាលចរាចរណ៍ខ្លះដែលធ្លាប់បានប្រព្រឹត្តខុសកន្លងមកផងដែរ។

សម្រាប់គ្រីស្តបរិស័ទ ការប្រព្រឹត្តបំពានច្បាប់ជាអំពើបាប។ ក្នុងលិខិតរបស់គ្រីស្តទូតប៉ូលបានសរសេរថា «មនុស្សគ្រប់រូបត្រូវស្តាប់បង្គាប់អាជ្ញាធរ ដ្បិតអំណាចទាំងឡាយសុទ្ធតែមកពីព្រះជាម្ចាស់ គឺព្រះអង្គបានតែងតាំងឱ្យមានអំណាចទាំងនោះឡើង។ ដូច្នេះ អ្នកដែលប្រឆាំងនឹងអាជ្ញាធរ ក៏ដូចជាប្រឆាំងនឹងរបៀបរៀបរយ ដែលព្រះជាម្ចាស់បានចាត់ចែងនោះដែរ ហើយអ្នកដែលប្រឆាំង មុខជាធ្វើឱ្យខ្លួនមានទោសមិនខាន។ អ្នកប្រព្រឹត្តអំពើល្អមិនខ្លាចអ្នកគ្រប់គ្រងស្រុកឡើយ មានតែអ្នកប្រព្រឹត្តអំពើអាក្រក់ប៉ុណ្ណោះដែលខ្លាច។

បើអ្នកមិនចង់ខ្លាចអាជ្ញាធរទេ ចូរប្រព្រឹត្តអំពើល្អទៅ នោះអាជ្ញាធរនឹងសរសើរអ្នកជាមិនខាន ដ្បិតលោកទាំងនោះជាអ្នកបម្រើព្រះជាម្ចាស់ ដើម្បីជំរុញអ្នកឱ្យប្រព្រឹត្តល្អ។ ផ្ទុយទៅវិញ បើអ្នកប្រព្រឹត្តអំពើអាក្រក់ ចូរខ្លាចទៅ ដ្បិតអាជ្ញាធរមិនមែនកាន់អំណាចជាអាសាឥតការទេ គឺគេជាអ្នកបម្រើព្រះជាម្ចាស់ ដើម្បីធ្វើទណ្ឌកម្ម ដាក់ទោសអ្នកដែលប្រព្រឹត្តអំពើអាក្រក់។ ដូច្នេះ ត្រូវស្តាប់បង្គាប់អាជ្ញាធរ មិនមែនដោយខ្លាចទទួលទណ្ឌកម្មប៉ុណ្ណោះទេ គឺធ្វើដោយមានមនសិការផង»។ (រ៉ូម១៣,១-៥)

សរុបមកវិញ សូមបន្តយកចិត្តទុកដាក់បន្តទៀតនូវការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានម៉ឺងម៉ាត់ ហើយពេលខ្លះការអនុវត្តច្បាប់នេះទៀតសោត វាមិនអាចជួយបានទាំងស្រុងទេ ដរាបណាយើងម្នាក់ៗគ្មានមនសិការនៅក្នុងការចូលរួម និងគ្មានការទទួលខុសត្រូវនៅក្នុងការប្រើប្រាស់ទ្រូងផ្លូវ។ សូមកុំយកច្បាប់ជាគ្រឿងស្វែងរកលាភសក្ការៈ! ហើយសូមកុំមើលងាយច្បាប់! ទាំងអស់គ្នាគួរតែចូលរួមអនុវត្តច្បាប់ដើម្បីសេចក្តីសុខ និង សុវត្ថិភាពរបស់យើងទាំងអស់គ្នា!៕

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខៈ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក



# អាមេរិកសម្តែងពីវឌ្ឍនភាពជាមួយកម្ពុជា ទាក់ទងនឹងកិច្ចសហប្រតិបត្តិការលើការបង្ក្រាបការជួញដូរមនុស្ស

*ដោយ ៖ ផល សុផានិត*

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា លោក Patrick Murphy បានសម្តែងពីវឌ្ឍនភាពជាមួយកម្ពុជាទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ជាពិសេសលើផ្នែកការបង្ក្រាបការជួញដូរមនុស្ស ខណៈប្រតិបត្តិការនេះបានឈានដល់ចាប់ជនល្មើសបានរហូតដល់បញ្ជូនទៅកាន់សហរដ្ឋអាមេរិកវិញនោះ។

ថ្លែងនៅក្នុងកិច្ចជំនួប ជាមួយសម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នារសៀលថ្ងៃទី២៦ ខែឧសភាឆ្នាំ២០២០នេះ នៅទីស្តីការក្រសួង លោក Patrick Murphy បានលើកឡើងថា វាជាកិច្ចសហប្រតិបត្តិការដ៏ល្អរវាងមន្ត្រីអនុវត្តច្បាប់របស់កម្ពុជា និងមន្ត្រីFBI របស់សហរដ្ឋអាមេរិកក្នុងកិច្ចការបង្ក្រាបការជួញដូរមនុស្ស និងរំលោភផ្លូវភេទលើកុមារនាពេលកន្លងមកនេះ។


*លោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ក្នុងពេលជួបសម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ **រូបភាព៖ ក្រសួងមហាផ្ទៃ***

លោកឯកអគ្គរដ្ឋទូត បានលើកឡើងទៀតថា៖ «លោកបានកត់សម្គាល់ថា ស្ថាប័នអនុវត្តច្បាប់នៅកម្ពុជាជាមួយអង្គភាពFBI របស់សហរដ្ឋអាមេរិកដែលបានសហការគ្នាទប់ស្កាត់និងបង្ក្រាប និងចាប់ខ្លួនជនល្មើស មួយចំនួនពាក់ព័ន្ធនឹងការរំលោភផ្លូវភេទលើកុមារមួយចំនួន ហើយបានបញ្ជូនទៅកាន់សហរដ្ឋអាមេរិកវិញ ដែលករណីនេះផងដែរ លោកបានកោតសរសើរកិច្ចខិតខំប្រឹងប្រែងថែរក្សាដល់សុវត្ថិភាពសាធារណៈទាំងកម្ពុជាក៏ដូចជានៅអាមេរិកនោះ»។

ជាមួយគ្នានោះដែរលោក Patrick Murphy ក៏បានលើកឡើងផងដែរថា អាមេរិកនៅតែបន្តជួយដល់ប្រទេសកម្ពុជាជានិច្ចបើទោះបីជាអាមេរិកកំពុងរងគ្រោះដោយសារបញ្ហា នៃការរីករាលដាលមេរោគកូវីដ១៩ក៏ដោយនោះ។

ជាងនេះទៅទៀត អាមេរិកក៏នៅតែបន្តជួយដល់កម្ពុជាខាងផ្នែកប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យាផងដែរ ដែលករណីនេះអាមេរិកបានផ្តល់វគ្គបណ្តុះបណ្តាលជាច្រើនដល់កម្ពុជាហើយនោះ។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ សម្តេចក្រឡាហោម ស ខេង ក៏បានថ្លែងអំណរអគុណចំពោះអាមេរិក ដែលបានជួយដល់កម្ពុជានាពេលកន្លងមក ហើយសម្តេចសូមសម្តែងការគាំទ្រទាំងស្រុងចំពោះការលើកឡើងរបស់លោក Patrick Murphy ទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងអាមេរិកនោះ។

សម្តេចក្រឡាហោម ក៏បានលើកឡើងអំពីកិច្ចសន្ទនារវាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជាមួយនឹងលោករដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកនាពេលកន្លងមកផងដែរ ដែលកិច្ចសន្ទនានេះបញ្ជាក់ឱ្យឃើញនូវភាពរីកចំរើនរវាងកិច្ចសហប្រតិបត្តិទ្វេភាគីរវាងកម្ពុជា និងអាមេរិក៕

# កម្មករព្យួរកិច្ចសន្យាការងារ បានចាប់ផ្តើមបើកប្រាក់ឧបត្ថម្ភ

*ដោយ ៖ ផល សុផានិត*

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា ចាប់ពីពេលនេះតទៅ កម្មករនិយោជិតព្យួរកិច្ចសន្យាការងារសរុបចំនួនជាង ៣ម៉ឺន ៣ពាន់នាក់ នៃរោងចក្រ សហគ្រាសចំនួន១១១ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ អាចបើកប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលបានតាមរយៈធនាគារឯកទេសវីង។

យោងតាមសេចក្តីជូនដំណឹង ស្តីពីការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិត ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣ នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ទទួលបាននៅរសៀលថ្ងៃទី២៦ ឧសភា ឆ្នាំ២០២០នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃ នៃការព្យួរកិច្ចសន្យាការងារ ដូចជា៖ ទឹកប្រាក់ចំនួនជាង ៦ម៉ឺនរៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃ ដល់១០ថ្ងៃ, ចំនួនជាង ១២ម៉ឺនរៀល (៣០ដុល្លារ) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ និងទឹកប្រាក់ជាង ១៦ម៉ឺនរៀល (៤០ដុល្លារ) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់១ខែ។

សេចក្តីជូនដំណឹងនេះ បានបញ្ជាក់ទៀតថា ដើម្បីចៀសវាងការលំបាកក្នុងការបង្វិលថវិកាសងរដ្ឋាភិបាលវិញក្នុងករណីរោងចក្រ សហគ្រាសសុំចូលធ្វើការមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះប្រាក់ឧបត្ថម្ភនឹងត្រូវចែកចេញជា ២ដង សម្រាប់កម្មករដែលព្យួរកិច្ចសន្យាការងារចាប់ពី២១ថ្ងៃ ដល់១ខែ, និងត្រូវបែងចែកជា ៤ដង សម្រាប់កម្មករដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដោយក្នុង១ដង ស្មើនឹងថវិកាចំនួន ៨ម៉ឺន ១ពាន់រៀល (២០ដុល្លារ)។


*លោកនាយករដ្ឋមន្ត្រីជួបសួរសុខទុក្ខកម្មការិនីនាពេលកន្លងមក។ **រូបភាព៖ ហ្វេសប៊ុកសម្តេចតេជោ***

ក្រសួងការងារលើកឡើងថា ធនាគារឯកទេស វីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរដ្ឋាភិបាលវិញ ប្រសិនជាកម្មករខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារ វីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ កម្មករត្រូវតែភ្ជាប់នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារដែលនៅជិតបំផុត។ ចំពោះថ្ងៃសៅរ៍ក្រសួង បានបញ្ជាក់បន្ថែមថា មិនតម្រូវឱ្យកម្មករបង់ថ្លៃនោះទេ នៅពេលបើកប្រាក់ឧបត្ថម្ភទាំងនេះ។

ក្នុងករណីកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ១១១ខាងលើមិនបានទទួលសារទូរសព្ទពី វីង សូមធ្វើការសាកសួរព័ត៌មានបន្ថែមទៅរដ្ឋបាលរោងចក្រ សហគ្រាស របស់ខ្លួនដោយផ្អែកលើខ្លឹមសារនៃសេចក្តីណែនាំរបស់ក្រសួង៕



# សម្តេច ហ៊ុន សែន៖ «ប្រជាពលរដ្ឋខ្មែរមិនតម្រូវឱ្យមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពថាគ្មានជំងឺឆ្លងកូវីដ១៩»

*ដោយ ៖ អមរិន្ទ ដានុត*

នាយករដ្ឋមន្ត្រីកម្ពុជាបានសម្រេចវិធានការដោះស្រាយជាផ្លូវការចំពោះពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនកម្ពុជា ដែលកំពុងធ្វើដំណើរឬមានបំណងធ្វើដំណើរពីក្រៅប្រទេស មិនតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់សុខភាពពីជំងឺកូវីដ១៩ទេ។

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានផ្សាយនៅលើបណ្តាញសង្គមផ្លូវការរបស់លោកនាកាលពីថ្ងៃពុធ ទី២៧ ខែឧសភា ឆ្នាំ២០២០ កន្លងទៅ ថាប្រជាពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនកម្ពុជា ហើយដែលកំពុងធ្វើដំណើរឬមានបំណងធ្វើដំណើរពីក្រៅប្រទេសវិលត្រឡប់ចូលមកកម្ពុជាវិញ មិនតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់សុខភាពថាគ្មានជំងឺឆ្លងកូវីដ១៩ ទេ។

លោកបានលើកឡើងបន្ថែមថា៖ «វិធានការនេះគឺនឹងជួយសម្រួលដល់ពលរដ្ឋនៅក្រៅប្រទេសឆាប់បានវិលត្រឡប់មកជួបជុំក្រុមគ្រួសារនៅក្នុងប្រទេសខ្លួនវិញ»។

សម្តេច ហ៊ុន សែនបានបញ្ជាក់បន្ថែមថា នៅពេលពួកគាត់វិលត្រឡប់មកដល់ប្រទេសកំណើតវិញ គឺតម្រូវឱ្យចូលពិនិត្យសុខភាពនិងពិនិត្យសំណាក និងដាក់ឱ្យស្នាក់នៅដាច់ដោយឡែកចំនួន១៤ថ្ងៃ រង់ចាំលទ្ធផលសំណាកថា តើមានរោគឆ្លងឬអត់រោគឆ្លង ទើបអនុញ្ញាតិឱ្យទៅលំនៅដ្ឋានវិញ៕

# យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតុលាការដំបូងរាជធានី-ខេត្ត



*លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការក្រសួងយុត្តិធម៌។ **រូបភាព៖ ក្រសួងមហាផ្ទៃ***

*ដោយ ៖ ផល សុផានិត*

យុទ្ធនាការ ដោះស្រាយ ការកកស្ទះសំណុំរឿងនៅតុលាការដំបូងរាជធានី-ខេត្ត ត្រូវបានប្រកាសចាប់ផ្តើមនៅព្រឹកថ្ងៃចន្ទ ទី១៨ ខែឧសភា ឆ្នាំ២០២០នេះ។

ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការក្រសួងយុត្តិធម៌ លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានគូសបញ្ជាក់ថា យុទ្ធនាការនេះមានគោលបំណងដើម្បីដោះស្រាយរឿងក្តីតុលាការដែលមានការកើនឡើង កាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារនិងដើម្បីលើកកម្ពស់សមត្ថភាពនិងប្រសិទ្ធភាពរបស់នីតិបុគ្គលដែលចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ។

លោករដ្ឋមន្ត្រីបានបន្តថា យុទ្ធនាការនេះត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ក្រសួងដែលមានគោលបំណង ដើម្បីបម្រើប្រជាជនឱ្យបានល្អនៅក្នុងវិស័យនេះ។

យោងតាមការចាត់តាំង លោក គឹម សន្តិភាព ត្រូវដឹកនាំក្រុមការងារទីមួយដែលគ្របដណ្តប់លើសាលាដំបូងចំនួន៤គឺ រាជធានីភ្នំពេញ កណ្តាល ព្រៃវែង និងខេត្តស្វាយរៀង។ ចំណែក លោក ឡុង ទរិទ្ធ ត្រូវដឹកនាំក្រុមការងារទីពីរ ដែលគ្របដណ្តប់លើសាលាដំបូងចំនួន៨ គឺ កំពង់ចាម កំពង់ធំ រតនគិរី មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង ក្រចេះ និងខេត្តត្បូងឃ្មុំ។

រីឯក្រុមការងារទី៣ គឺដឹកនាំដោយលោក ជីវ សុងហាក់ ដែលគ្របដណ្តប់លើសាលាដំបូងចំនួន៧ គឺ សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ ឧត្តរមានជ័យ និងខេត្តប៉ៃលិន។ ដោយឡែកក្រុមការងារទីបួនចុងក្រោយគឺ ដឹកនាំដោយលោក ជិន ម៉ាលីន ដែលគ្របដណ្តប់លើសាលាដំបូងចំនួន៥ គឺ កោះកុង ព្រះសីហនុ កំពត តាកែវ និងខេត្តកំពង់ស្ពឺ។

សម្រាប់គណៈកម្មការថ្មីនេះ មានភារៈកិច្ចដឹកនាំនិងសម្របសម្រួលការងាររួមលើការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ នេះគឺជាយុទ្ធនាការមួយដើម្បីលើកកម្ពស់សមត្ថភាព ស្ថាប័នក្នុងការបម្រើសេវាយុត្តិធម៌ឱ្យបានល្អ ជាពិសេសកាត់បន្ថយភាពចង្អៀតណែននៅពន្ធនាគារ។

បើយោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃបានឱ្យដឹងថា បច្ចុប្បន្ននៅកម្ពុជាមានអ្នកកំពុងជាប់ឃុំ សរុបប្រមាណជាជិត៤ម៉ឺននាក់ (៣៨.៩១១) ក្នុងនោះ ១ភាគ៣ គឺជាអ្នកជាប់ឃុំ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន៕

# សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន) គ្រោងនឹងដាក់អនុវត្តន៍ឆាប់ៗ

*ដោយ ៖ អមរិទ្ធ ដានុត*

សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន)នឹងដាក់ឱ្យមានកិច្ចប្រជុំពិភាក្សាក្នុងអន្តរក្រសួងដែលមានការពាក់ព័ន្ធ ដើម្បីពិភាក្សាឱ្យបានលំអិតដោយធ្វើយ៉ាងណាឱ្យអនុក្រឹត្យនេះកាន់តែល្អនិងអាចយកទៅអនុវត្តបាន។ នេះបើតាមការលើកឡើងរបស់លោក ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃនារសៀលថ្ងៃអង្គារទី១៩ ខែឧសភា ឆ្នាំ២០២០នៅក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ។

លោក ប៊ុន ហុន បាននិយាយនៅក្នុងកិច្ចប្រជុំនេះថា សេចក្តីព្រាងអនុក្រឹតស្តីពីការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន) នេះ ធ្លាប់បានយកមកពិភាក្សាម្តងរួចមកហើយ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ហើយអនុក្រឹត្យនេះ ក៏បានស្នើសុំឱ្យមន្ត្រីជំនាញយកទៅសិក្សាបន្ត។

លោកថ្លែងថា ៖«អាកាសយានគ្មានមនុស្សបើក (ដ្រូន) ប្រសិនបើក្នុងវិស័យកសិកម្មឬក្នុងវិស័យពាណិជ្ជកម្ម មិនមានការបារម្ភនោះទេ ប៉ុន្តែបើយកទៅប្រើប្រាស់ប៉ះពាល់ទៅដល់សន្តិសុខជាតិ ជាការបារម្ភយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីកិច្ចប្រជុំព្រាងអនុក្រឹត្យនេះរួច យើងក៏នឹងអាចប្រជុំជាមួយអន្តរក្រសួងដែលពាក់ព័ន្ធដូចជា ក្រសួងការពារជាតិ លេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីពិភាក្សាឱ្យអនុក្រឹត្យនេះកាន់តែល្អនិងអាចយកទៅអនុវត្តបាន»។

ក្នុងឱកាសនោះ ឧត្តមសេនីយ៍ឯក ប៉ាង រ៉ាស៊ី អនុប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ បាននិយាយថា កាលពីពេលប្រជុំលើកទី១ អង្គប្រជុំបានសម្រេចកែសម្រួលនៅលើនិយមន័យបន្ថែមមួយចំនួន រីឯចំណុចទាក់ទងនឹងសមត្ថកិច្ច អង្គប្រជុំបានកែសម្រួលបញ្ចូលបន្ថែមនូវការបណ្តុះបណ្តាល ការហ្វឹកហាត់នៃការប្រើអាកាសយានគ្មានមនុស្សបើក (ដ្រូន) ហើយក៏បានសម្រេចបន្ថែមដាក់លក្ខខណ្ឌមួយចំនួនឱ្យអ្នកផលិតឬអ្នកកែច្នៃត្រូវចុះបញ្ជីការបច្ចេកទេសឬមានប្លង់រួមពីបច្ចេកទេសដើម្បីដាក់ជូនសមត្ថកិច្ចផងដែរ។

យោងតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃបានឱ្យដឹងថា អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងអាកាសយានគ្មានអ្នកបើក (ដ្រូន) គ្រប់ប្រភេទដើម្បីធានាសុវត្ថិភាព សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេសកម្ពុជា។ អនុក្រឹត្យនេះក៏មានគោលបំណងកំណត់អំពីការចុះបញ្ជិការ ការអនុញ្ញាតផលិត ការកែច្នៃ ការប្រើប្រាស់ និងការកំណត់តំបន់ហាមឃាត់ការប្រើប្រាស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន)។

ប្រភពដដែលបានឱ្យដឹងទៀតថា អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះអាកាសយានគ្មានមនុស្សបើក (ដ្រូន) គ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា លើកលែងតែការផលិត ការកែច្នៃ និងការប្រើប្រាស់ដែលបម្រើឱ្យវិស័យការពារជាតិនិងសន្តិសុខដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល៕

# រដូវបិទនេសាទឆ្នាំ២០២០ចាប់ផ្តើមបិទពីដើមខែមិថុនារហូតដល់ចុងខែតុលា

*ដោយ ៖ អមរិទ្ធ ដានុត*

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសបិទរដូវនេសាទនៅតាមទីតាំងទៅតាមពេលវេលាដែលកំណត់ និងការនេសាទត្រូវបានអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ឧបករណ៍សម្រាប់តែការនេសាទលក្ខណៈគ្រួសារតែប៉ុណ្ណោះ ដើម្បីចូលរួមចំណែកថែរក្សានិងការពារធនធានជលផលឱ្យបានគង់វង្ស។

លោក អេង ជាសាន ប្រធានរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញនូវសេចក្តីជូនដំណឹងមួយស្តីពីរដូវបិទនេសាទឆ្នាំ២០២០ ថា រដូវបិទនេសាទសម្រាប់ការនេសាទនៅក្នុងដែននេសាទទឹកសាបនឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ ដែលមានខេត្តទាំងអស់ជុំវិញបឹងទន្លេសាប និងតាមបណ្តាខេត្តមួយចំនួនដូចជា កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រះវិហារ ប៉ៃលិន ឧត្តរមានជ័យ និងរាជធានីភ្នំពេញ និងខេត្តកណ្តាល ផ្នែកខាងជើងចតុមុខ។

លោក អេង ជាសានបានបញ្ជាក់ទៀតថា ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ចំពោះដែននេសាទទឹកសាប ដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខដែលរួមមានរាជធានីភ្នំពេញផ្នែកខាងត្បូងចតុមុខ ខេត្តកណ្តាល ព្រៃវែង តាកែវ កំពង់ស្ពឺ និងខេត្តស្វាយរៀង។

នៅក្នុងរយៈពេលបិទនេសាទនេះ អ្នកនេសាទទាំងអស់ត្រូវប្រើប្រាស់តែឧបករណ៍នេសាទលក្ខណៈគ្រួសារប៉ុណ្ណោះ ឯចំពោះឧបករណ៍ដូចជា អួន ម៉ាញ់ ចៃ៉ា ជន សាបនាម និងឈ្នក់ មិនអនុញ្ញាតឱ្យប្រើឡើយក្នុងរដូវបិទនេសាទនេះ។ ដោយឡែកសម្រាប់ឧបករណ៍មងអាចធ្វើការនេសាទបានតែប្រវែង១០០ម៉ែត្រប៉ុណ្ណោះ។



លោក អេង ជាសាន បានលើកឡើងថា៖ «រដ្ឋបាលជលផលសង្ឃឹមថាសាធារណជននិងអ្នកនេសាទទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ដើម្បីចូលរួមចំណែកថែរក្សានិងការពារធនធានជលផលឱ្យបានគង់វង្ស សម្រាប់ប្រជាពលរដ្ឋខ្មែរជំនាន់ក្រោយៗទៀត»៕





# វត្ថុសិល្បៈចំនួន៧១១បំណែកបានចុះបញ្ជីសារពើភណ្ឌនិង៥៣១បំណែកកំពុងដំណើរការចុះបញ្ជីដើម្បីសម្គាល់អត្តសញ្ញាណ

*ដោយ ៖ ផល សុផានិត*

ក្រុមការងារចុះបញ្ជីបេតិកភណ្ឌរូបីនៃអាជ្ញាធរជាតិអប្សរា សម្រេចចុះបញ្ជីវត្ថុសិល្បៈបានចំនួន៧១១បំណែក ដែលប្រមូលបានពីប្រជាជននិងនៅតាមប្រាសាទទាំង៩១ក្នុងរមណីយដ្ឋានអង្គរ ឱ្យមានសុវត្ថិភាព និងមានអត្តសញ្ញាណត្រឹមត្រូវ សម្រាប់ជាប្រយោជន៍ប្រើប្រាស់ទៅថ្ងៃក្រោយ។



*លោក ឈូក សុម៉ាឡា មន្ត្រីទទួលបន្ទុកចុះបញ្ជីបេតិកភណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ។ **អាជ្ញាធរជាតិអប្សរា***

លោក ឈូក សុម៉ាឡា មន្ត្រីទទួលបន្ទុកចុះបញ្ជីបេតិកភណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការឱ្យដឹងថា បំណែកវត្ថុសិល្បៈទាំង៧១១បំណែកដែលក្រុមការងារបានចុះបញ្ជីសារពើភណ្ឌរួចរាល់នោះ គឺភាគច្រើនជាចម្លាក់ធ្វើពីថ្មភក់មាន៖ សិលាចារឹក ចម្លាក់ទេវរូប បល្ល័ង្កឬជើងទម្រ បំណែកផ្តែរ បំណែកហោជាង បំណែកសសរពេជ្រ បំណែកក្បាច់លម្អផ្សេងៗ កុលភាជន៍ និងវត្ថុធ្វើពីលោហៈមួយចំនួនទៀត។

ក្រៅពីការចុះបញ្ជីវត្ថុសិល្បៈដែលបានទទួលពីប្រជាជន និងកំណាយស្រាវជ្រាវផ្សេងៗខាងលើ ក្រុមចុះបញ្ជីក៏បានចុះបញ្ជីវត្ថុសិល្បៈដែលនៅជុំវិញបរិវេណប្រាសាទទាំង៩១បានមួយចំនួនដែរ។

ការចុះបញ្ជីវត្ថុសិល្បៈដែលនៅតាមប្រាសាទទាំង៩១នេះ គឺមានគោលបំណងចងក្រងឯកសារ កំណត់អត្តសញ្ញាណវត្ថុសិល្បៈទាំងនោះ ដើម្បីចូលរួមទប់ស្កាត់ការចល័តឬបាត់បង់ដោយប្រការណាមួយជាយថាហេតុ។ នៅក្នុងទម្រង់នៃការកំណត់អត្តសញ្ញាណនេះ គឺបានផ្តល់ព័ត៌មានយ៉ាងជាក់លាក់អំពីប្រភេទចម្លាក់ ប្រភពវត្ថុធាតុ ទំហំ ទីតាំង កាលបរិច្ឆេទ ថតរូប និងការពិពណ៌នាផ្សេងៗ ហើយព័ត៌មានទាំងនេះឯងដែលអាចជួយសម្រួលដល់ការងារជួសជុល និងការទាមទារត្រឡប់មកវិញក្នុងករណីបាត់បង់ណាមួយ។

លោក សុម៉ាឡា បន្តទៀតថា ការងារចុះបញ្ជីពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការរក្សាកេរមរតកបេតិកភណ្ឌ ត្បិតអតីតរាជធានីនៃចក្រភពអង្គរ មានវិសាលភាពធំធេងណាស់ ហើយនៅមានវត្ថុសិល្បៈជាច្រើនទៀតដែលកំពុងនៅរាយប៉ាយលើដីនិងក្រោមដី ដែលត្រូវបន្តចុះបញ្ជីកំណត់អត្តសញ្ញាណវត្ថុទាំងនោះជាបន្តបន្ទាប់។

តួយ៉ាងដូចជាថ្មីៗនេះ ក្រុមការងារចុះបញ្ជីសារពើភណ្ឌបានប្រមូលចម្លាក់ព្រះពុទ្ធបដិមា និងវត្ថុសិល្បៈផ្សេងទៀតដែលមានចំនួន៥៣១បំណែកពីរោងឆ្នាំខាងត្បូងប្រាសាទអង្គរវត្ត យកមករក្សាទុកនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ដើម្បីធ្វើការសិក្សាបន្ថែមរង់ចាំការងារជួសជុលនាពេលខាងមុខ។ កិច្ចការចុះបញ្ជីវត្ថុសិល្បៈបេតិកភណ្ឌរូបីនៅក្នុងរមណីយដ្ឋានអង្គរនៅតែបន្តជាប្រចាំ ដើម្បីចូលរួមថែរក្សា និងការពារវត្ថុសិល្បៈនានានៅតាមប្រាសាទទាំង៩១ ឱ្យមានអត្តសញ្ញាណច្បាស់លាស់ ទប់ស្កាត់ការចល័តនិងការបាត់បង់៕





*បំណែកវត្ថុសិល្បៈទាំង៧១១បំណែក។ **រូបភាព៖ អាជ្ញាធរជាតិអប្សរា***

# លោក ឃួង ស្រេង៖ «បន្តអប់រំប្រជាពលរដ្ឋនិងបន្តអនុវត្តការការពាររលកទី២នៃការចម្លងមេរោគកូវីដ១៩ នៅរាជធានីភ្នំពេញ»

*ដោយ ៖ អមរិទ្ធ ដានុត*

អភិបាលសាលារាជធានីភ្នំពេញ លោក ឃួង ស្រេង បានណែនាំទៅដល់អាជ្ញាធរខណ្ឌទាំង១៤ក្នុងប្រទេសកម្ពុជា ឱ្យបន្តអប់រំសុខភាពជូនប្រជាពលរដ្ឋពីការអនុវត្តវិធានការការពាររលកទី២នៃជំងឺកូវីដ១៩ (COVID-19)

លោក ឃួង ស្រេង បានចេញសេចក្តីណែនាំ៧ចំណុច ដើម្បីបន្តទប់ស្កាត់ និងការពារការរីករាលដាលជាថ្មីនៃជំងឺនេះ ដោយលោកបានបង្គាប់ឱ្យអាជ្ញាធរបន្តចាត់តាំងកម្លាំងដើម្បីផ្សព្វផ្សាយអប់រំ និងណែនាំប្រជាពលរដ្ឋដែលរស់នៅនិងស្នាក់នៅក្នុងមូលដ្ឋានខណ្ឌ សង្កាត់ ជាពិសេស កម្មករ-កម្មការិនី នៅតាមបណ្តារោងចក្រនានាក្នុងរាជធានីភ្នំពេញ ឱ្យអនុវត្តនូវវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគ កូវីដ១៩ និងកែប្រែឥរិយាបថនៃការរស់នៅប្រចាំថ្ងៃឱ្យស្របតាមបរិបទនៃការប្រយុទ្ធនឹងមេរោគកូវីដ១៩ ដោយត្រូវលាងដៃជាប្រចាំពាក់ម៉ាស់ ឬប្រើប្រាស់ក្រមា និងត្រូវខ្ទប់មាត់នៅពេលក្អក ឬកណ្តាស់ ព្រមទាំងត្រូវបន្តអនុវត្តគម្លាត សុវត្ថិភាពសង្គម និងរក្សាគម្លាតសុវត្ថិភាពបុគ្គលជាចាំបាច់។

លោកបានបន្តហាមឃាត់ការជួបជុំ ឬការប្រមូលផ្តុំ ដូចជា កម្មវិធីជប់លៀង ឬការជួបជុំបែបសាសនាទាំងអស់។ល។ នៅក្នុងមូលដ្ឋានរហូតដល់ខែកញ្ញា ឆ្នាំ២០២០។លោក ឃួង ស្រេង បានបញ្ជាក់នៅក្នុងសេចក្តីណែនាំអាជ្ញាធរខណ្ឌទាំង១៤ថា៖ «ត្រូវចុះត្រួតពិនិត្យ និងតាមដាននៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងកន្លែងលក់ដូរនានាឱ្យអនុវត្តវិធានការបង្ការនិងទប់ស្កាត់ការរីករាលដាលមេរោគកូវីដ១៩ ក្នុងនោះម្ចាស់អាជីវកម្មទាំងអស់ត្រូវរៀបចំដែលឬអាល់កុលលាងដៃ នៅមុខច្រកទ្វារចេញ-ចូល និងត្រូវចាត់តាំងបុគ្គលិកឱ្យធ្វើការវាស់កម្តៅភ្ញៀវទាំងអស់មុននឹងអនុញ្ញាតឱ្យចូលក្នុងទីតាំងអាជីវកម្មទាំងនោះ។ ក្នុងករណីដែលម្ចាស់ទីតាំងអាជីវកម្មខាងលើ មិនអនុវត្តតាមការណែនាំទេនោះ រដ្ឋបាលរាជធានីភ្នំពេញនឹងបិទអាជីវកម្មជាបណ្តោះអាសន្ន»។

លោកបន្តទៀតថា ត្រូវបន្តចុះត្រួតពិនិត្យនិងតាមដានការអនុវត្តនូវវិធានការផ្អាកជាបណ្តោះអាសន្ននូវទីតាំងអាជីវកម្មមួយចំនួនដូចជា ក្លឹបហាត់ប្រាណ រោងភាពយន្ត KTV ក្លឹបកម្សាន្ត (រង្គសាល ខារ៉ាអូខេ ឌីស្កូថេក បៀរហ្គាឌិន) អាជីវកម្មម៉ាស្សាសុខភាព និងស្ប៉ា។ ចុះស្រង់ស្ថិតិប្រជាពលរដ្ឋដែលទើបអញ្ជើញមកពីក្រៅប្រទេស និងណែនាំឱ្យពួកគាត់ធ្វើចត្តាឡីស័ក និងតាមដានសុខភាពផ្ទាល់ខ្លួនជាចាំបាច់ ក្នុងរយៈពេល១៤ថ្ងៃ ហើយក្នុងករណីសង្ស័យ ឬមានអាការៈមិនស្រួលខ្លួន ដូចជា ក្តៅខ្លួន ក្អក ឈឺបំពង់ក ឬពិបាកដកដង្ហើម ត្រូវទៅពិនិត្យព្យាបាលជំងឺនៅ មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតជាបន្ទាន់ ឬត្រូវទំនាក់ទំនងតាមទូរសព្ទទៅលេខ១១៥៕

# កិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការងារអាស៊ានបង្ហាញពីភាពរឹងមាំនៃស្មារតីសាមគ្គីភាព

*ដោយ ៖ អមរិទ្ធ ដានុត*

រដ្ឋមន្ត្រីការងារអាស៊ានបានអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពី៖ «ការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅលើមុខរបរនិងការងារ» នាកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការងារអាស៊ានកាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ដែលសេចក្តីថ្លែងការណ៍រួមនោះមាន៩ចំណុច ប៉ុន្តែក្នុងនោះកិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការផ្តល់កិច្ចគាំទ្រដល់ជីវភាព និងសុខភាពរបស់កម្មករនិយោជិត ពលករទេសន្តរប្រវេសន៍និងអ្នកធ្វើការក្នុងវិស័យដែលរងហានិភ័យខ្ពស់, ការធានាថាកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ឬព្យួរកិច្ចសន្យាការងារទទួលបានការផ្តល់អត្ថប្រយោជន៍សមស្របតាមច្បាប់ លិខិតបទដ្ឋាន និងលទ្ធភាពនៃប្រទេសជាសមាជិក, ការផ្តល់សេវាថែទាំសុខភាពដល់កម្មករនិយោជិតដែលឆ្លងជំងឺកូវីដ១៩, ការពង្រឹងបន្ថែមប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទីផ្សារការងារ បទដ្ឋានសុវត្ថិភាពនិងសុខភាពការងារ និងប្រព័ន្ធគាំពារសង្គម, និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយក្នុងការទំនាក់ទំនងនិងពិគ្រោះយោបល់ក្នុងអំឡុងពេលមានការរឹតត្បិតជាបណ្តោះអាសន្ន។

រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង ដែលបានចូលរួមកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការងារអាស៊ានតាមរយៈប្រព័ន្ធវីដេអូ (Video Conference) ស្តីពី "ការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅលើមុខរបរនិងការងារ" នៅក្រសួងការងារកាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០បានចែករំលែកព័ត៌មានអំពីគោលនយោបាយនិងវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាក្រសួងការងារបានដាក់ចេញដើម្បីបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ក្នុងការជួយឧបត្ថម្ភគាំទ្រដល់កម្មករនិយោជិត និយោជក និងជនងាយរងគ្រោះដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩។

កិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការងារអាស៊ានមានរដ្ឋមន្ត្រីក្រសួងធនធានមនុស្សប្រទេសម៉ាឡេស៊ី ក្នុងអាណត្តិជាប្រធានបានដឹកនាំកិច្ចប្រជុំនេះ ព្រមជាមួយគ្នានោះដែរ នៅក្នុងវគ្គនៃកិច្ចប្រជុំបើកចំហរក៏មានការចូលរួមពីលោក Guy Ryder អគ្គនាយកអង្គការអន្តរជាតិខាងការងារ (ILO) ក៏បានចូលរួម ភាពជាដៃគូជាមួយអាស៊ាន ដើម្បីរួមគ្នាក្នុងការទប់ស្កាត់ នៃការរីករាលដាល និងផលប៉ះពាល់នៃជំងឺកូវីដ១៩នេះ។

កិច្ចប្រជុំពិសេសនេះ ជាការបង្ហាញពីភាពរឹងមាំនៃស្មារតីសាមគ្គីភាពអាស៊ាន ដូចដែលមានចែងក្នុងបាវចនាអាស៊ាន "សហគមន៍តែមួយ វាសនាតែមួយ" ក្នុងការឆ្លើយតបរួមគ្នារបស់អាស៊ានចំពោះផលប៉ះពាល់នៃជំងឺកូវីដ១៩៕

# ការបាត់បង់សត្វដំរីឈ្មោល «ប៉ាក់ម៉ៃ» ជាការសោកស្ដាយសម្រាប់ប្រទេសកម្ពុជា




*ប៉ាក់ម៉ៃ ជាដំរីឈ្មោលដែលស្ថិតក្នុងការគាំពារថែរក្សា ប៉ុន្តែបានស្លាប់កាលពីខែឧសភា។* ***រូបភាព៖ សារព័ត៌មានថ្មីថ្មី***

*ដោយ ៖ អមរិន្ទ ដានុត*

ដំរីមួយក្បាលឈ្មោះ ប៉ាក់ម៉ៃ បានស្លាប់កាលពីយប់ថ្ងៃព្រហស្បតិ៍ទី២១ ខែឧសភា ឆ្នាំ២០២០ ដោយសារជំងឺ។ ការបាត់បង់សត្វដំរីមួយក្បាលនេះ បានធ្វើឱ្យក្រសួងបរិស្ថាននិងអង្គការ សមាគមធ្វើការលើការអភិរក្សសត្វដំរីមានការសោកស្ដាយជាខ្លាំង។

ដំរីប៉ាក់ម៉ៃ ជាដំរីឈ្មោលមួយក្បាលក្នុងចំណោមដំរីទាំង៤ក្បាលដែលបាននឹងកំពុងស្ថិតក្នុងការគាំពារថែរក្សានិងអភិរក្សដោយគម្រោងមូលនិធិរបស់សមាគមអែរ៉ាវនៅក្នុងខេត្តរតនគីរី ប្រទេសកម្ពុជា។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់សមាគមអភិរក្សដំរីអែរ៉ាវត្តាដែល*អ្នកនាំសារ* ទទួលបាន បានបញ្ជាក់ថា ក្រុមការងារនិងក្រុមហ្សរបស់សមាគមនេះបានកត់សម្គាល់ឃើញថា នៅពេលព្រឹកថ្ងៃដែលដំរីនេះបានស្លាប់ ដំរីប៉ាក់ម៉ៃមានអាការៈរាគរុសខុសប្លែកធម្មតានិងបន្ទាប់មកបានដួលដោយពុំអាចងើបឈរឡើងវិញបាន។ ភ្លាមៗនោះក្រុមការងារនិងថ្នាក់ដឹកនាំសមាគមបានទាក់ទងគ្នានិងរាយការណ៍ជូនស្ថាប័នជំនាញពាក់ព័ន្ធនិងអង្គការជំនាញដំរីដើម្បីផ្ដល់ការគាំទ្របច្ចេកទេសបសុពេទ្យសង្គ្រោះដំរីនេះឱ្យបានទាន់ពេលវេលា តែជាអកុសល ទោះបីជាមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ យ៉ាងហ្មត់ចត់ពីក្រុមជំនាញនិងបសុពេទ្យមកពីគ្លីនិក AngroVet រួមទាំងក្រុមការងារយ៉ាងណា ក៏ដំរីឈ្មោះប៉ាក់ម៉ៃពុំអាចស៊ូទ្រាំនឹងអាការៈជំងឺរបស់ខ្លួនតទៅទៀតបានឡើយ នៅយប់ថ្ងៃដដែល។

ក្នុងខណៈនេះសមាគម បាននឹងកំពុងបន្តសហការជាមួយស្ថាប័នរដ្ឋ អាជ្ញាធរមានសមត្ថកិច្ច និងក្រុមអ្នកជំនាញពាក់ព័ន្ធដើម្បីពិនិត្យនិងធ្វើកោសល្យវិច្ឆ័យរកមូលហេតុពិតប្រាកដអំពីអាការៈជំងឺនិងការស្លាប់របស់ដំរីនេះ។

សេចក្ដីប្រកាសព័ត៌មានដដែលនេះបានបន្តថា ការបាត់បង់ដំរីឈ្មោះប៉ាក់ម៉ៃ គឺជាការបាត់បង់ធនធានសត្វដំរីដែលជាបេតិកភណ្ឌធម្មជាតិរបស់ជាតិមួយ ដែលសមាគមបានខិតខំគាំពារថែរក្សានិងអភិរក្សអស់ជាច្រើនឆ្នាំកន្លងមកដោយមានការគាំទ្រពីក្រសួងបរិស្ថានតាមរយៈកម្មវិធីការងារគាំពារបរិស្ថាននិងសង្គម និងបណ្ដាស្ថាប័នជាតិផ្សេងទៀតផងដែរ។

ការបាត់បង់ជីវិតរបស់ដំរីប៉ាក់ម៉ៃនេះដែរ ក្រសួងបរិស្ថានក៏បានសម្ដែងការសោកស្ដាយចំពោះការបាត់បង់សត្វដំរីឈ្មោះ «ប៉ាក់ម៉ៃ» នេះ ដែលការបាត់បង់សត្វដំរីប៉ាក់ម៉ៃជាការបាត់បង់សត្វដំរីជាប្រភេទសត្វកម្រនៅកម្ពុជា។

យោងតាមក្រសួងបរិស្ថាន នៅក្នុងប្រទេសកម្ពុជា ដំរីអាស៊ីមានចំនួនប្រមាណពី៤០០ទៅ៦០០ក្បាលដែលភាគច្រើនរស់នៅក្នុងតំបន់ជួរភ្នំក្រវាញ តំបន់ខ្ពង់រាបខាងជើងទន្លេសាប និងតំបន់ខ្ពង់រាបភាគខាងកើតក្នុងខេត្តមណ្ឌលគិរី ដែលជាតំបន់ជីវៈចម្រុះដ៏សំបូរបែប ប្រព័ន្ធអេកូឡូស៊ី និងមានទីជម្រាលអំណោយផលដល់ការរស់នៅរបស់សត្វដំរី និងសត្វព្រៃផ្សេងៗទៀត។

ដំរីអាស៊ីកំពុងរងការគំរាមកំហែងធ្ងន់ធ្ងរនៅទូទាំងដែនជម្រករបស់វាក្នុងសកលលោក ហើយត្រូវបានចាត់បញ្ចូលជាប្រភេទជិតផុតពូជនៅក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)៕

# រដ្ឋាភិបាលត្រៀមផែនការជួយសង្គ្រោះពលរដ្ឋក្នុងគ្រាគ្រោះទឹកជំនន់



*ផ្ទះដែលរងការខូចខាតដោយការបាក់ស្រុតច្រាំងទន្លេនារដូវទឹកជំនន់នាឆ្នាំកន្លងមក។* ***រូបភាព៖ ស៊ីអេសស៊ី***

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានដាក់ចេញនូវផែនការសកម្មភាពមួយចំនួន ដើម្បីត្រៀមឆ្លើយតប និងជួយសង្គ្រោះដល់ប្រជាពលរដ្ឋក្នុងរដូវទឹកជំនន់នៅឆ្នាំនេះ ខណៈការព្យាករណ៍កម្ពស់ទឹកជាបឋម បានបង្ហាញថា ឆ្នាំនេះកម្ពស់ទឹកអាចខ្ពស់ជាងឆ្នាំមុន។

កាលពីរសៀលថ្ងៃអង្គារ លោក ទេសរដ្ឋមន្ត្រី គន់ គីម អនុប្រធានទី១ គណៈកម្មការធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានដឹកនាំកិច្ចប្រជុំប្រគល់ភារកិច្ច និងអនុវត្តផែនការសកម្មភាពរៀបចំឆ្លើយតបក្នុងរដូវទឹកជំនន់ ជាមួយមន្ត្រីអគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ។

លោក សៀក វិចិត្រ អ្នកនាំពាក្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានមានប្រសាសន៍កាលពីថ្ងៃពុធថា ក្នុងកិច្ចប្រជុំនោះ ថ្នាក់ដឹកនាំគណៈកម្មាធិការ បានបែងចែកតួនាទី និងការទទួលខុសត្រូវមួយចំនួនដល់មន្ត្រីឱវាទ ដោយមានការត្រៀមកងកម្លាំងមានសមត្ថកិច្ចប្រមាណជាង ៧០០នាក់ រួមនិងសម្ភារៈជួយសង្គ្រោះនានា ក្នុងការត្រៀមជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះ ក្នុងករណីមានទឹកជំនន់កើតឡើង។

លោកបន្តថា៖ «ក្រៅពីនោះ ក៏មានគម្រោងរៀបចំទីទួលសុវត្ថិភាពសម្រាប់ជម្លៀសប្រជាពលរដ្ឋនៅតាមបណ្ដាខេត្តមួយចំនួនផងដែរ ប្រហែលជាអាចធ្វើរួចឆាប់ៗនេះនៅតាមបណ្ដាខេត្តមួយចំនួន [ដែលធ្លាប់រងគ្រោះ] ហើយយើងក៏មានប្រព័ន្ធប្រកាសព័ត៌មានជាមុន តាមលេខទូរស័ព្ទ ១២៩៤ (Early Warning System) សម្រាប់ផ្ញើសារជាសំឡេង ទៅប្រជាពលរដ្ឋដែលបានចុះឈ្មោះក្នុងប្រព័ន្ធនេះ ដើម្បីឱ្យពួកគាត់បានដឹងជាមុន ប្រសិនបើមានគ្រោះទឹកជំនន់កើតឡើងក្នុងតំបន់របស់ពួកគាត់រស់នៅ»។

ទោះយ៉ាងណា លោក សៀក វិចិត្រ បានបញ្ជាក់ថា នេះជាកិច្ចប្រជុំរៀបចំចាត់ចែងភារកិច្ចដល់មន្ត្រីពាក់ព័ន្ធក្នុងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយប៉ុណ្ណោះ ហើយសម្រាប់ផែនការសកម្មភាពនៅថ្នាក់ក្រោមជាតិនឹងធ្វើឡើងនៅពេលខាងមុខបន្តទៀត ទៅតាមស្ថានភាពជាក់ស្ដែង។

តែយ៉ាងណា លោកបានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ មានការប្រុងប្រយ័ត្នខ្ពស់ និងត្រៀមខ្លួនជាមុនផងដែរ ក្នុងករណីបើសិនមានបញ្ហាគ្រោះទឹកជំនន់កើតឡើង។

លោក ចាន់ យុត្ថា អ្នកនាំពាក្យក្រសួងធនធានទឹក និងឧតុនិយម បានមានប្រសាសន៍កាលពីថ្ងៃពុធថា យោងតាមការព្យាករណ៍កម្ពស់ទឹកទន្លេ លើកទី១ ឃើញថា កម្ពស់ទឹកឆ្នាំនេះមានកម្ពស់ ៩,៧០ម៉ែត្រ អាចមានកម្រិតខ្ពស់ជាងឆ្នាំមុន ដែលអាចចាត់ទុកថាជាជំនន់ប្រភេទមធ្យម។

លោកថា៖ «ទោះជាយ៉ាងណា យើងនឹងធ្វើការតាមដាន ព្យាករណ៍កម្ពស់ទឹកបន្តទៀត ហើយក្នុងករណីដែលមានការប្រែប្រួលយ៉ាងម៉េចនោះ យើងនឹងជូនដំណឹងជាបន្តបន្ទាប់»។

បើតាមលោក ចាន់ យុត្ថា បញ្ហាទឹកជំនន់ គឺមិនមែនសុទ្ធតែផ្ដល់ផលអវិជ្ជមានទាំងនោះទេ ប៉ុន្តែវាក៏ផ្ដល់ផលប្រយោជន៍មួយចំនួនផងដែរដល់វិស័យកសិកម្ម ប្រសិនបើមានទឹកជំនន់តិចតួច ឬមធ្យមនោះ។

លោកថា៖ «ប្រសិនបើមានទឹកជំនន់ធំហួសហេតុដូចកាលឆ្នាំ២០១១ និង ២០១៣ នោះ វាផ្ដល់នូវគ្រោះមហន្តរាយច្រើន ប៉ុន្តែបើសិនជាជំនន់តិចតួច ឬមធ្យម នោះវានឹងផ្ដល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់យើងវិញ ព្រោះវាអាចហូរទៅចាក់បំពេញបឹងទន្លេសាប ដែលជាជម្រកមច្ឆាជាតិដ៏សំខាន់ និងហូរចាក់ចូលព្រែក បឹងបួរនានា ដើម្បីបំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ហើយជំនន់នោះក៏នាំមកនូវដីល្បាប់សម្រាប់បង្កើនជីវជាតិដី និងសម្លាប់សត្វល្អិតមួយចំនួនក្នុងវិស័យកសិកម្មផងដែរ»។

យោងតាមការព្យាករណ៍កម្ពស់ទឹកជំនន់ទន្លេមេគង្គលើកទី១ប្រចាំឆ្នាំ ២០២០ របស់ក្រសួងធនធានទឹក និងឧតុនិយម កាលពីសប្ដាហ៍មុន បានឱ្យដឹងថា ចាប់ពីខែមិថុនា ដល់ខែតុលា បាតុភូត Neutral មាន៦០% និងបាតុភូត El Nino មាន១០% និងបាតុភូត La Nina មាន៣០% ដែលស្ថានភាពបែបនេះ នឹងធ្វើឱ្យភ្លៀងធ្លាក់ក្នុងកម្រិតពីធម្យមទៅច្រើន ទាំងក្នុងអាងទន្លេមេគង្គ និងនៅក្នុងប្រទេសកម្ពុជា។ ក្រសួងបន្តថា តាមរយៈកត្តាអាកាសធាតុ ការវិភាគទំនាក់ទំនងរវាងកម្ពស់ទឹកអប្បបរមានិងអតិបរមា ព្រមទាំងការវិភាគលើវដ្តទឹក បង្ហាញថា ស្ថានភាពទឹកជំនន់ឆ្នាំនេះអាចជាប្រភេទជំនន់មធ្យម៕ *ប្រភព៖ ខ្មែរថាមស៍*

# ប្រធានព្រឹទ្ធសភា ទទួលជួបឯកអគ្គរដ្ឋទូតថ្មីនៃទីម័រឡេស្តេ

*ដោយ ៖ ផល សុផានិត*

ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេប្រចាំកម្ពុជា លោក អេមេនេហ្សុដូ គូប៉ា ឡូប៉េស៍ (Ermenegildo "Kupa" Lopes) បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់ប្រទេសកម្ពុជា ចំពោះសមាជិកភាពរបស់ប្រទេសទីម័រឡេស្តេជាសមាជិករបស់អាស៊ាន សមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO និងសមាជិកអន្តរសភាអាស៊ាន AIPA។ ការថ្លែងបែបនេះ ក្នុងជំនួបពិភាក្សាជាមួយសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា កាលពីព្រឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។

លោកឯកអគ្គរដ្ឋទូតគូសបញ្ជាក់ថា ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ប្រទេសទីម័រឡេស្តេតែងតែគាំទ្រដល់ជំហររបស់ប្រទេសជាសមាជិកអាស៊ានទាំងអស់ ជាពិសេសតែងគាំទ្រដល់ជំហររបស់ព្រះរាជាណាចក្រកម្ពុជាដែលជាសមាជិកអាស៊ាន ហើយនេះគឺជានយោបាយការបរទេសដ៏រឹងមាំរបស់ប្រទេសទីម័រឡេស្តេ។

លោក អេមេនេហ្សុដូ គូប៉ា ឡូប៉េស៍ បន្តថា ក្នុងអណត្តិនៃបេសកកម្មការទូតនៅកម្ពុជា លោកនឹងខិតខំជំរុញនូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងសភានៃប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្ដូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ ព្រមទាំងកិច្ចសហប្រតិបត្តិការបច្ចេកទេស។



*លោក អេមេនេហ្សុដូ គូប៉ា ឡូប៉េស៍ ជួបពិភាក្សាជាមួយសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។* ***រូបភាព៖ ព្រឹទ្ធសភា***

លោកឯកអគ្គរដ្ឋទូតបានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាបដែរថា អគ្គស្នងការនគរបាលទីម័រឡេស្ត ចង់ឱ្យមានកិច្ចសហប្រតិបត្តិការល្អជាមួយនឹងអគ្គស្នងការនគរបាលជាតិនៃប្រទេសកម្ពុជា ខាងការបណ្ដុះបណ្ដាលជំនាញសន្តិសុខ និងភាសាអង់គ្លេស។

ទាក់ទងជាមួយការប្រយុទ្ធនឹងកូវីដ១៩ លោក ឡូប៉េស៍ បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់នៃប្រទេសកម្ពុជា ដែលមានយុទ្ធសាស្ត្រ និងវិធានការយ៉ាងល្អក្នុងការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ចំពោះប្រជាជនកម្ពុជា ជាពិសេសស្ថានទូតទីម័រឡេស្តេ និងនិស្សិតទីម័រឡេស្តេ ដែលកំពុងសិក្សានៅប្រទេសកម្ពុជា បានទទួលនូវការគ្រប់គ្រងដ៏ល្អប្រសើរផងដែរ។

ជាការឆ្លើយតបសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានសម្ដែងនូវសេចក្ដីរីករាយ និងស្វាគមន៍។ សម្ដេចប្រធានមានជំនឿជឿជាក់ថា ក្នុងអាណត្តិបេសកកម្មរបស់ឯកឧត្តមអគ្គរដ្ឋទូតពិតជានឹងខិតខំប្រឹងប្រែងដើម្បីពង្រឹងនិងពង្រីកនូវទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែមានការរីកចម្រើននិងរឹងមាំថែមទៀត ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជននិងប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភា បានថ្លែងអំណរគុណចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតដែលបានវាយតម្លៃខ្ពស់ចំពោះការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩ នៅប្រទេសកម្ពុជា ដោយចាត់ទុកថា នេះគឺជាការលើកទឹកចិត្តយ៉ាងក្លៀវក្លាដល់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ ក្នុងនាមព្រឹទ្ធសភា សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដល់ទឹកចិត្តដ៏ប្រពៃរបស់ឯកឧត្តមដែលកាលពីពេលថ្មីៗនេះបានផ្ដល់អំណោយជាម៉ាស់និងទឹកលាងដៃដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីចូលរួមបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។

សម្ដេចប្រធានព្រឹទ្ធសភាបានស្វាគមន៍ចំពោះគោលបំណងដែលចង់ឱ្យមានកិច្ចសហប្រតិបត្តិការល្អរវាងអគ្គស្នងការនគរបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេនិងអគ្គស្នងការនគរបាលនៃព្រះរាជាណាចក្រកម្ពុជា៕

សូមរំលឹកថា ទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ បានភ្ជាប់ទំនាក់ទំនងការទូតចាប់តាំងពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ហើយសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ បានបើកនិវេសនដ្ឋានដំបូងនៅកម្ពុជា នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥។ ប្រទេសទាំងពីរក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានៃកិច្ចព្រមព្រៀងស្ដីពីសេដ្ឋកិច្ច ពាណិជ្ជកម្ម បច្ចេកទេស និងការងារផងដែរ៕

# អ្នកជំនាញ៖ អាស៊ានត្រូវតែបើកដំណើរការសកម្មភាពសេដ្ឋកិច្ចឡើងវិញ

*ដោយ ៖ អរិយបុត្រ*

បណ្ដាប្រទេសនៅអាស៊ានត្រូវបានគេអះអាងថា គួរតែប្រញាប់បើកដំណើរការសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេឡើងវិញ បើមិនដូចនោះទេ វិបត្តិដោយសារតែការបិទនឹងអាចមានសភាពកាន់តែធ្ងន់ធ្ងរសម្រាប់សេដ្ឋកិច្ច។ អ្នកជំនាញការនិងជាអ្នកការទូតអាស៊ានមួយរូបបានប្រាប់សារព័ត៌មាននៅក្នុងតំបន់ដោយមិនបញ្ចេញអត្តសញ្ញាណថា អាស៊ានដាច់ខាតត្រូវតែស្វែងរកដំណោះស្រាយដើម្បីបើកសកម្មភាពសេដ្ឋកិច្ចឡើងវិញជាបន្ទាន់ បើទោះបីជាមេរោគកំពុងតែរីករាលដាលនៅក្នុងតំបន់ក៏ដោយ អ្នកជំនាញខាងការទូតដដែលបានអះអាងថា សកម្មភាពសេដ្ឋកិច្ចត្រូវតែដំណើរការ តែក៏ត្រូវដើរទន្ទឹមគ្នានឹងវិធានការដើម្បីធ្វើយ៉ាងណាឱ្យការឆ្លងនៃជំងឺស្ថិតនៅក្នុងសភាពដែលអាចគ្រប់គ្រងបាន។

រហូតមកដល់ពេលនេះ សកម្មភាពសេដ្ឋកិច្ចដែលកំពុងតែប្រឈមមុខនឹងវិបត្តិខ្លាំងបំផុតរបស់អាស៊ាននោះ គឺការនាំចេញនិងវិស័យទេសចរណ៍។ ការនាំចេញរបស់អាស៊ាន និងវិស័យទេសចរណ៍ សឹងតែស្ថិតនៅក្នុងសភាពដែលស្ទើរតែដួលរលំ ដែលទាមទារឱ្យត្រូវតែមានចរន្តឡើងវិញ។ ដើម្បីឱ្យភ្ញៀវទេសចរនិងសកម្មភាពផ្លាស់ប្ដូរទំនិញ ព្រមទាំងពាណិជ្ជកម្មដំណើរការឡើងវិញនោះ គឺបណ្ដាប្រទេសនៅអាស៊ានទាំងអស់ត្រូវតែធ្វើយ៉ាងណាវិនិយោគនិងជះលំហូរទុនទៅទម្លាក់នៅលើវិស័យសុខាភិបាល និងលើកកំពស់ស្តង់ដាសុខមាលភាពនិងធ្វើយ៉ាងណាក៏ដោយត្រូវកសាងនូវជំនឿទុកចិត្តដើម្បីឱ្យសកម្មភាពអាជីវកម្មនានាលើវិស័យទាំងពីរនេះអាចនឹងចាប់ផ្ដើមស្ដារឡើងវិញ។

តាមការព្យាករណ៍វិបត្តិដែលបណ្ដាលមកពីការរីករាលដាលដោយសារតែការផ្ទុះនៃមេរោគកូវីដ១៩ នេះមកលើអាស៊ាន គឺមិនតូចតាចនោះឡើយ ហើយគេបានធ្វើការព្យាករណ៍ថា សេដ្ឋកិច្ចអាស៊ានយ៉ាងហោចណាស់ក៏ត្រូវតែចំណាយពេលនៅក្នុងការស្ដារឡើងវិញ គឺមិនក្រោមរយៈពេល១៨ខែនោះឡើយ។ គិតត្រឹមចុងខែឧសភាកន្លងទៅនេះ អត្រាឆ្លងនិងការរីករាលដាលមេរោគកូវីដ១៩ នៅអាស៊ាននៅតែមាន ទោះបីជាអត្រាស្លាប់តិចជាងតំបន់នានា ប៉ុន្តែវានៅតែជាបញ្ហាប្រឈមមួយហើយគេដឹងថា នៅពេលនេះអត្រាឆ្លងភាគច្រើនមាននៅក្នុងប្រទេសសិង្ហបុរី ដែលមានអ្នកឆ្លងសរុបប្រមាណជាជាង ៣៣.២០០នាក់ទៅហើយ បន្ទាប់មកប្រទេសឥណ្ឌូនេស៊ីដែលមានចំនួនជាង ២៤.០០០នាក់ ចំណែកហ្វីលីពីនវិញស្ថិតនៅក្នុងចំនួនប្រមាណជាជាង១៥.៥០០នាក់ ដោយឡែកម៉ាឡេស៊ីមានប្រមាណជា៧.៦០០នាក់។

បណ្ដាប្រទេសផ្សេងៗទៀតនៅទូទាំងតំបន់អាស៊ានគឺសុទ្ធតែមានករណីឆ្លង រួមទាំងកម្ពុជាផងដែរ ប៉ុន្តែមកដល់ពេលនេះអត្រានៃការបាត់បង់ជីវិតនៅកម្ពុជានៅមិនទាន់មាននៅឡើយទេ។

ដោយសារតែករណីឆ្លងភាគច្រើននៅអាស៊ាន ជាពិសេសដោយសារតែជនអន្តោប្រវេសន៍ដូចជាករណីនៅក្នុងប្រទេសសិង្ហបុរី បានធ្វើឱ្យអ្នកការទូតនៅក្នុងតំបន់អាស៊ាននៅពេលនេះកំពុងតែរិះគិតនិងចាត់វិធានការរឹតត្បិតសកម្មភាពរបស់ក្រុមជនអន្តោប្រវេសន៍ដែលខុសច្បាប់។ ករណីប្រទេសម៉ាឡេស៊ីនៅពេលនេះ កំពុងតែចាត់វិធានការយ៉ាងតឹងរឹងបំផុតទៅលើក្រុមជនអន្តោប្រវេសន៍ខុសច្បាប់ដែលត្រូវបានគេរត់ពន្ធពីប្រទេសផ្សេងៗចូលទៅក្នុងប្រទេសម៉ាឡេស៊ី ដោយនៅពេលនេះកំពុងតែរឹតបន្តឹងរាល់ប៉ុស្តិ៍ត្រួតពិនិត្យនៅតាមព្រំដែនសមុទ្រនិងដីគោក ហើយផ្លូវអាកាសដ៏ដូចគ្នាផងដែរ។ ការរឹតបន្តឹងក៏ដូចជាការបង្ការនូវចលនានៃការផ្លាស់ប្ដូររបស់ជនអន្តោប្រវេសន៍ខុសច្បាប់ឆ្លងតាមព្រំដែន គឺជារឿងដែលត្រូវបានអ្នកជំនាញនិងអ្នកការទូតនៅអាស៊ានរូបនោះបានអះអាងថា ជាច្រកនិងវិធានការទប់ស្កាត់មួយដ៏វិជ្ជមានសម្រាប់បណ្ដាប្រទេសទាំងអស់នៅក្នុងតំបន់នេះ។

លោកបានអះអាងនិងបានសង្កត់ធ្ងន់ថា សកម្មភាពសេដ្ឋកិច្ចនានាគួរតែបើកដំណើរការ ប៉ុន្តែរដ្ឋសមាជិកនានា នៅអាស៊ានត្រូវតែយកចិត្តទុកដាក់នៅក្នុងការបង្ការនូវចលនារបស់ប្រជាពលរដ្ឋខុសច្បាប់ពីព្រោះថា ចលនានេះពិបាកនឹងគ្រប់គ្រង។ លោកបានបញ្ជាក់ថា៖ «ខ្ញុំប្រាកដចិត្តថាគ្រប់ប្រទេសទាំងអស់ត្រូវតែចាំបាច់បើកដំណើរការសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ប៉ុន្តែប្រទេសទាំងនោះក៏ត្រូវតែខិតខំធ្វើយ៉ាងណាការពារ និងទប់ស្កាត់ ហើយធានាថា ប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួនមានសុវត្ថិភាពនិងមានសុខភាពល្អ ហើយត្រូវតែរឹតបន្តឹងនូវការរីករាលដាលនៃមេរោគនេះ។

អ្នកជំនាញការនៅក្នុងតំបន់បានលើកឡើងថា ដើម្បីស្ដារសេដ្ឋកិច្ចអាស៊ានឡើងវិញនោះ ដាច់ខាតអាស៊ានត្រូវតែរកច្រកដើម្បីកែលំអរនិងស្ដារនូវច្រកដ៏សំខាន់នៃសេដ្ឋកិច្ចគឺការនាំចេញ ទេសចរណ៍ និងការជំរុញដំណើរការសកម្មភាពនៅក្នុងស្រុកនិងនៅក្នុងតំបន់ ដោយសារតែពេលនេះទីផ្សារអាស៊ានមានប្រមាណជា ៦០០លាននាក់ដែរ។ ដំណោះស្រាយសម្រាប់ស្ដារសកម្មភាពសេដ្ឋកិច្ចបាននោះ គេបានជំរុញឱ្យរដ្ឋជាសមាជិកអាស៊ាននានា ការពារពលរដ្ឋខ្លួនកុំឱ្យឆ្លង ហើយជំរុញដំណើរការប្រើប្រាស់និងសកម្មភាពនៅក្នុងស្រុកនឹងរៀបចំការពង្រីកទៅតំបន់ ប៉ុន្តែដាច់ខាតត្រូវដើរទៅតាមនិយាមនៃស្តង់ដារសុវត្ថិភាពមួយដែលនៅពេលនេះគេបានជឿជាក់ថា អ្នកជំនាញនៅក្នុងបណ្ដាប្រទេសអាស៊ានកំពុងតែសិក្សានិងរិះរកដើម្បីស្ដារសេដ្ឋកិច្ចតំបន់នេះហើយ៕

# វិនិយោគិនមួយរូបៈ «ជន្លេនក៏មានតម្លៃ និងតួនាទីផ្នែកសេដ្ឋកិច្ចសំខាន់មួយដែរ»

*ដោយ ៖ អរិយបុត្រ*

សត្វជន្លេនរស់នៅក្នុងដីដែលមានរូបរាងគួរឱ្យខ្ពើមរអើម ហើយរហូតដល់អ្នកខ្លះស្អប់ខ្ពើមហើយខ្លាចថែមទៅទៀតនោះ តាមពិតវាមានតម្លៃផ្នែកសេដ្ឋកិច្ចនិងមានតម្លៃផ្នែកអេកូឡូស៊ី ព្រមទាំងមានតួនាទីដ៏សំខាន់នៅក្នុងការជួយសំអាតកាកសំណល់ជាពិសេស គឺកាកសំណល់សរីរាង្គផ្សេងៗផងដែរ។

ទាក់ទិននឹងតួនាទីរបស់សត្វជន្លេននេះលោក គីម នីដូ ជាស្ថាបនិកនិងជានាយកប្រតិបត្តិនៃក្រុមហ៊ុន ទ្វីង អាហ្គ្រី តិច (T.W.I.N Agri Tech Co. Ltd) បានថ្លែងឱ្យដឹងថា សព្វថ្ងៃនេះសត្វជន្លេនជាប្រភពដ៏សំខាន់មួយនៅក្នុងដំណើរការផលិតកម្មជីកំប៉ុស្តិនិងជីអាចម៍ជន្លេនដែលជាផលិតផលសំខាន់របស់ក្រុមហ៊ុន។

លោកបានបន្តទៀតថា ដោយសារតែជន្លេននិងសម្រាមសរីរាង្គនេះសព្វថ្ងៃលោកអាចផលិតជីសម្រាប់លក់ជូនអតិថិជនប្រមាណពី៣០០ទៅ៥០០តោន តែបើនៅរដូវប្រាំងលោកអាចមានសមត្ថភាពផលិតបានរហូតដល់ទៅ១០០០តោននៅក្នុងមួយខែ ដើម្បីផ្តល់ជូនកសិករនិងអ្នកដែលចូលចិត្តដាំដំណាំ។

លោកបានបញ្ជាក់ថា ជន្លេនដែលកំពុងតែជួយក្រុមហ៊ុននៅក្នុងការរួមចំណែកកាត់បន្ថយកាកសំណល់ និងផលិតជាជីនេះ គឺជាជន្លេននៅក្នុងស្រុក និងបាននាំចូលមួយចំនួនពីប្រទេសសិង្ហបុរី។ ដូច្នេះ វាគឺជាសត្វដែលមានប្រយោជន៍មួយដែលអាចជួយដល់កសិករនៅក្នុងស្រុកដើម្បីបង្កើតនូវជីធម្មជាតិ។

លោកបានបន្តទៀតថា៖ «សម្រាប់ខ្ញុំ ជន្លេនគឺជាសត្វមានប្រយោជន៍ខ្លាំងណាស់សម្រាប់ជាសង្វាក់ផលិតកម្មហើយសម្រាប់បរិស្ថាន វាជួយបោសសំអាតកាកសំណល់សម្រាប់កសិករ វាជួយឱ្យដីមានជីវជាតិ ងាយស្រូបយកទឹកមិនធ្វើដីឱ្យខ្សោះឬដីរឹងគ្មានជីវជាតិ»។





លោក គីម នីដូ (ឆ្វេង) ស្ថាបនិកនិងជានាយកប្រតិបត្តិនៃក្រុមហ៊ុន ទ្វីង អាហ្គ្រី តិច និងធុងបន្លែសរីរាង្គ (ស្តាំ)។ **រូបភាព៖ ក្រុមហ៊ុន ទ្វីង អាហ្គ្រី តិច**





(ឆ្វេង) ជីជីអាចម៍ជន្លេនដែលក្រុមហ៊ុនកំពុងបានផលិត (ស្តាំ) បុគ្គលិកបម្រើការកំពុងរៀបចំដឹកជញ្ជូនជីទៅដល់អតិថិជន។ **រូបភាព៖ ក្រុមហ៊ុន ទ្វីង អាហ្គ្រី តិច**

ក្រុមហ៊ុនកែច្នៃសំរាមមួយនេះត្រូវបានគេដឹងថា ជាក្រុមហ៊ុនមួយកំពុងតែប្រមូលយកកាកសំណល់មកកែច្នៃធ្វើជាវត្ថុធាតុដើម ដើម្បីជំរុញផលិតកម្មដែលបានរួមចំណែកផ្តល់ការងារធ្វើជូនពលរដ្ឋដោយផ្ទាល់ចំនួន៣៥រូបនិងបានរួមសកម្មភាពជួយដល់វិស័យកសិកម្មដែលជាវិស័យទ្រទ្រង់សេដ្ឋកិច្ចជាតិមួយដ៏ចំបងផងដែរ។

លោកបានបញ្ជាក់ឱ្យដឹងថា៖ «ក្រុមហ៊ុនបានចាប់ផ្តើមដំបូងតែពីរនាក់គត់ គឺរូបលោកផ្ទាល់និងដៃគូជាជនជាតិសិង្ហបុរី បន្ទាប់មកយើងមានកម្មករចំនួនពីរនាក់ ហើយរហូតមកដល់ឥឡូវនេះយើងមានបុគ្គលិកនិងកម្មករចំនួន៣៥នាក់»។

រហូតមកដល់ពេលបច្ចុប្បន្ននេះ នៅរាជធានីភ្នំពេញមានបរិមាណកាកសំណល់ប្រមាណជា៣,០០០តោននៅក្នុងមួយថ្ងៃ ដោយឡែកក្រុមហ៊ុនទ្វីង អាហ្គ្រី តិច ក៏អាចចូលរួមចំណែកនៅក្នុងការកាត់បន្ថយបរិមាណសំរាមបានប្រមាណជាពី៣០ទៅ៤៥តោនផងដែរនៅក្នុងមួយថ្ងៃ។

លោក គីម នីដូ បានបញ្ជាក់ថា ក្នុងមួយថ្ងៃយើងបានចូលរួមប្រមូលកាកសំណល់ពីផ្សាររោងចក្រ និងសិប្បកម្មផ្សេងៗនៅក្នុងបរិមាណពី៣០ទៅ៤៥តោន។

លោកបានបន្តទៀតថា សំរាមដែលក្រុមហ៊ុនលោកប្រមូល គឺជាសំរាមប្រភេទសរីរាង្គដែលវារលួយដូចជាបន្លែ កាកអំពៅ សំបកដូង និងកាកសំណល់សរីរាង្គមួយចំនួនទៀត។

ផលិតផលជីដែលក្រុមហ៊ុនផលិតមានពីរប្រភេទ ហើយបានលក់ចេញនៅក្នុងតម្លៃខុសគ្នាដោយប្រភេទជីកំប៉ុស្តនៅក្នុងមួយបាវមានទំងន់៥០គកមានតម្លៃ១០ដុល្លារ និង១២៥ដុល្លារនៅក្នុងមួយតោន ប៉ុន្តែសម្រាប់ជីអាចម៍ជន្លេនវិញមួយបាវមានតម្លៃ១២ដុល្លារ និងមួយតោនគឺតម្លៃ១៥៥ដុល្លារ។

ឆ្លងតាមផលិតផលជីដែលផលិតពីសំរាមនិងសត្វជន្លេនទាំងនេះ ក្រុមហ៊ុនក៏បានកែច្នៃចេញជាផលិតផលមួយទៀត គឺធុងដាំបន្លែសរីរាង្គមួយប្រភេទដែលអាចបំពេញមុខងារយ៉ាងហោចណាស់បីព្រមគ្នានៅក្នុងពេលតែមួយ។

លោកបានឱ្យដឹងថា ធុងកែច្នៃនេះ ត្រូវការទំហំដីត្រឹមតែ១ម៉ែត្រការ៉េតែប៉ុណ្ណោះ ប៉ុន្តែគេអាចដាំបន្លែបានពី៥៥ទៅ៦០គុម្ពឯណោះ។ ធុងបន្លែសរីរាង្គនេះអាចដាំនៅកន្លែងធ្វើការ នៅគេហដ្ឋានបាន ហើយថែមទាំងមានកន្លែងសម្រាប់បំបែងកាកសំណល់ផ្ទះបាយដោយមិនមានក្លិនសម្រាប់យកទឹកនិងកាកសំណល់ធ្វើជាជីដាក់បន្លែនេះដោយផ្ទាល់បានថែមទៀតផង។

លោកបានបញ្ជាក់ថា៖ «នៅក្នុងមួយធុងនេះមានបន្លែនៅក្នុងនោះស្រាប់ មានជី មានជន្លេន ហើយនឹងមានកន្លែងសម្រាប់កែច្នៃកាកសំណល់ថែមទៀត»។

ធុងដាំបន្លែសរីរាង្គដែលកែច្នៃនេះ ត្រូវបានគេដឹងថា វាមានកំពស់ប្រមាណជា១ម៉ែត្រ ដោយនៅកណ្តាលមានប្រហោងមួយ។ សារៈប្រយោជន៍របស់ប្រហោងនៅលើធុងជ័រកែច្នៃនេះ គឺ សម្រាប់ដាក់កម្ទេចកម្ទីកាកសំណល់ពីផ្ទះបាយដែលរួមមានកាកសំណល់បន្លែ ផ្លែឈើ ជាពិសេសប្រភេទបន្លែរលួយផ្សេងៗ លើកលែងតែខ្លាញ់ដាក់ចូល។ កាកសំណល់ទាំងនេះនឹងត្រូវបានបំបែកធាតុជាជីនិងទឹកដោយពពួកសត្វជន្លេនដែលមាននៅក្នុងធុងនេះ។ ទឹកដែលបន្សល់ពីកាកសំណល់ទាំងនេះមិនមានក្លិននោះទេ ហើយនៅក្នុងធុងនេះមានតម្រងមួយសម្រាប់គេត្រងយកទឹកទាំងនេះធ្វើជាជីស្រោចទៅលើបន្លែវិញនៅលើធុងទាំងនេះក៏បាន។

តាមការពន្យល់ដោយកម្មករដែលកំពុងតែបម្រើការងារប្រចាំថ្ងៃនៅទីលានកែច្នៃសម្រាមនោះផ្ទាល់បានឱ្យដឹងថា កាកសំណល់ដែលបានមកពីការបំបែកធាតុនៃសំរាមតាមផ្ទះ ដែលគេអាចដាក់នៅក្នុងធុងនេះគឺអាចយកទៅចិញ្ចឹមត្រីក៏បានផងដែរ ពីព្រោះវាជាអាហារធម្មជាតិសុទ្ធសាធ។

លោកបានបញ្ជាក់ថា៖ «ជាទូទៅធុងបន្លែនេះអាចជួយអតិថិជនបានច្រើន ទីមួយជាកន្លែងលម្អ ទីពីរជាកន្លែងសម្រាប់កាត់បន្ថយកាកសំណល់ផ្ទះបាយ និងទី៣ជាឧបករណ៍សម្រាប់កាត់បន្ថយស្ត្រេស ហើយក៏អាចឱ្យយើងទទួលបាននូវបន្លែស្រស់ និងធម្មជាតិដែលយើងអាចដាំដោយខ្លួនយើងផងដែរ»។

រហូតមកដល់ពេលនេះគេដឹងថា នៅក្នុងមួយគ្រួសារៗអាចបន្សល់ទុកនូវកាកសំណល់ប្រមាណជាពី៣ទៅ៥គីឡូក្រាម ហើយនៅក្នុងចំណោមនោះកាកសំណល់ពីផ្ទះបាយមានប្រមាណជា៥០ទៅ៧០ភាគរយនៃកាកសំណល់ប្រចាំថ្ងៃ។ កាកសំណល់ទាំងនោះត្រូវបានដាក់លាយឡំគ្នា ប៉ុន្តែរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ឱ្យពលរដ្ឋចេះញែកកាកសំណល់សម្រាប់ងាយស្រួលនៅក្នុងប្រតិបត្តិការកែច្នៃកាកសំណល់ទាំងនោះឡើងវិញ៕







# ថៃកំពុងរៀបចំជំរុញវិស័យទេសចរណ៍ក្នុងស្រុកដើម្បីទប់ទល់នឹងវិបត្តិកូវីដ១៩

*ដោយ ៖ អរិយបុត្រ*

ខណៈពេលដែលវិស័យទេសចរណ៍នៅក្នុងប្រទេសថៃកំពុងរងថ្មបាក់ ដោយសារតែការដួលរលំនៃវិស័យអាកាសចរណ៍ ក៏ដូចជាទេសចរណ៍និងសេវាកម្មនានា ដោយសារតែកូវីដ១៩ នៅពេលនេះ អ្នកជំនាញថៃកំពុងតែរៀបចំជំរុញវិស័យទេសចរណ៍នៅក្នុងស្រុក។

ទីភ្នាក់ងារផែនការរដ្ឋនៃប្រទេសថៃបានឱ្យដឹងថា រដ្ឋាភិបាលគ្រោងនឹងជំរុញវិស័យទេសចរណ៍ក្នុងស្រុកក្នុងត្រីមាសទី៣ ដើម្បីជួយទ្រទ្រង់សេដ្ឋកិច្ចដែលកំពុងជួបការលំបាក ខណៈជំងឺកូវីដ១៩ វាយប្រហារលើការធ្វើដំណើរជាសកល និងការប្រើប្រាស់ក្នុងស្រុក។

ទីភ្នាក់ងារនេះបានឱ្យដឹងទៀតថា ប្រទេសពឹងលើការនាំចេញនិងវិស័យទេសចរណ៍នេះ អាចនឹងធ្លាក់ចុះសេដ្ឋកិច្ចពី៥ភាគរយទៅ៦ភាគរយនៅឆ្នាំនេះ ដែលជាស្ថានភាពអាក្រក់បំផុតចាប់តាំងពីវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧-៩៨ ដោយសារតែការផ្ទុះឡើងនៃមេរោគកូវីដ។

លោក ថោសាផន សិរីស៊ុមផាន លេខាធិការទូទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមបានថ្លែងថា៖ «ក្បាលម៉ាស៊ីនផ្សេងទៀតត្រូវបានបិទក្នុងអំឡុងពេលកូវីដ១៩ ហើយមានតែវិធានការចំណាយនិងវិធានការពន្ធរបស់រដ្ឋាភិបាលប៉ុណ្ណោះចេញមុខជួយដល់សេដ្ឋកិច្ច»។

លោកបាននិយាយថា រដ្ឋាភិបាលនឹងរៀបចំកញ្ចប់ថវិកាសម្រាប់ការធ្វើដំណើរក្នុងស្រុកចាប់ពីខែកក្កដា។ លោកបន្ថែមថា ព័ត៌មានលម្អិតនឹងបានដឹងច្បាស់នៅពាក់កណ្តាលខែមិថុនា។

លោកនិយាយថា៖ «វិស័យទេសចរណ៍គួរតែជាកត្តាជំរុញសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ប្រសិនបើស្ថានភាពប្រសើរឡើង យើងអាចបើកឱ្យភ្ញៀវទេសចរចូលមកលេង»។ ផែនការជំរុញទេសចរណ៍ក្នុងស្រុកនឹងត្រូវផ្តល់ហិរញ្ញប្បទានដោយប្រាក់ ចំនួន១លានលានបាត ដែលរដ្ឋាភិបាលនឹងខ្ចីគេដើម្បីកាត់បន្ថយផលប៉ះពាល់នៃកូវីដ១៩លើការងារ៕

# រមណីដ្ឋានអង្គររកចំណូលបានជាង១៨លានដុល្លារអាមេរិក ក្នុងរយៈពេល៥ខែដំបូងក្នុងឆ្នាំនេះ

*ដោយ ៖ ផល សុផានិត*

ឧទ្យានជាតិអង្គរដែលស្ថិតនៅក្នុងខេត្តសៀមរាប រកចំណូលបានត្រឹមតែ ១៨,០២១ លានដុល្លារអាមេរិកប៉ុណ្ណោះ ពីការលក់សំបុត្រជូនភ្ញៀវទេសចរក្នុងរយៈពេល៥ខែដើមឆ្នាំ២០២០នេះ។ នេះបើតាមការផ្សាយឱ្យដឹងកាលពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២០ ដោយគ្រឹះស្ថានអង្គរ។

គ្រឹះស្ថានអង្គរ បានឱ្យដឹងថា នៅរយៈពេល៥ខែ ចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២០ ភ្ញៀវបរទេសចំនួន៣៨៦,០៩៣ នាក់ បានទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ធ្លាក់ចុះ៦៥.៤៦ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៩។ ចំណែកឯប្រាក់ចំណូលវិញ រយៈពេល៥ខែឆ្នាំនេះ ទទួលបានចំនួន១៨,០២១,៣៣៦ដុល្លារ ធ្លាក់ចុះ៦៤.១៨ភាគរយ។

សម្រាប់ប្រាក់ចំណូលជាង១៨លានដុល្លារនេះ ត្រូវដកចំនួនជាង៧៧ម៉ឺនដុល្លារអាមេរិក សម្រាប់ឧបត្ថម្ភដល់មូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីជួយសម្រួលដល់ដំណើរការ ព្យាបាលកុមារដោយឥតគិតថ្លៃនៅមន្ទីរពេទ្យគន្ធបុប្ផាទាំង៥ទីតាំង ក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប។

វិស័យទេសចរណ៍របស់ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសដទៃទៀតនៅលើពិភពលោកត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយជំងឺកូវីឌ ១៩៕


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .....
.....។ **រូបភាព៖ ស៊ីអេសស៊ី**

# ពលរដ្ឋកម្ពុជាមួយចំនួនសូមឲ្យសមត្ថកិច្ចញែកឲ្យដាច់រឿងជួញដូរ និងការប្រើប្រាស់គ្រឿងញៀន



ជនអនាថារស់នៅតាមដងផ្លូវដែលជាអ្នកប្រើប្រាស់សារធាតុញៀន (ការហិត)។ ស៊ីអេសស៊ី



ជនបរទេសដែលប្រើប្រាស់គ្រឿងញៀនត្រូវបានបង្ក្រាប។ នគរបាលជាតិ

*ដោយ៖ ....*

ប្រជាពលរដ្ឋកម្ពុជាមួយចំនួនបានជំរុញឱ្យសមត្ថកិច្ចជួយញែកឱ្យដាច់រវាងករណីជួញដូរគ្រឿងញៀននិងករណីដែលប្រើប្រាស់គ្រឿងញៀន ដោយសារតែពួកគេកត់សំគាល់ឃើញថា សឹងតែទាំងអស់នៃការបង្ក្រាបបទល្មើសគ្រឿងញៀនសមត្ថកិច្ចហាក់មិនផ្តាច់ករណីទាំងនេះចេញពីគ្នាឡើយ។

ថ្លែងប្រាប់ *អ្នកនាំសារ* នៅក្នុងលក្ខណៈប្រយ័ត្នប្រយែងខ្ពស់ ប្រជាពលរដ្ឋកម្ពុជាវ័យ៤៥ឆ្នាំដែលជាមន្ត្រីរាជការមួយរូបនិងបានប្រាប់ឈ្មោះលោកថា សុវណ្ណ កក្កដា បានឱ្យដឹងថា តាមការសង្កេតផ្ទាល់ខ្លួនរបស់លោកចំពោះករណីបង្ក្រាបនូវបទល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀនដែលសមត្ថកិច្ចបង្ក្រាបបានកន្លងមកគឺហាក់ដូចជាមានភាពមិនច្បាស់លាស់រវាងករណីជួញដូរនិងករណីប្រើប្រាស់គ្រឿងញៀន។

លោក សុវណ្ណ កក្កដា បានរៀបរាប់បន្ថែមថា តាមការអានអត្ថបទកាសែតប្រចាំថ្ងៃរហូតមកដល់ពេលនេះ ការបង្ក្រាបបទល្មើសគ្រឿងញៀនមានសឹងតែរាល់ថ្ងៃ គ្រាន់តែភាគច្រើនជាករណីតូចតាច ហើយជាទូទៅបទល្មើសគ្រឿងញៀនដែលសមត្ថកិច្ចយកមកដាក់បន្ទុកនិងអនុវត្តនូវវិធានការចាប់ខ្លួនភាគច្រើនដូចជាមិនមានការស៊ើបអង្កេតច្បាស់លាស់ឡើយ។ ប្រតិបត្តិការដែលទំនងភាគច្រើនដូចជាចៃដន្យ ដែលមិនបានធ្វើការស៊ើបអង្កេតឱ្យបានស៊ីជម្រៅ មុនពេលចាប់ឬឃាត់ខ្លួនឡើយ។

លោកបានបន្តទៀតថា ភាគច្រើននៃជនល្មើសដែលសមត្ថកិច្ចឃាត់ខ្លួនយកមកចុះកាសែតនោះ គឺអនុវត្តនៅពេលដែលពួកគេល្បាតហើយក៏ប្រទះឃើញជនសង្ស័យក៏ធ្វើការឃាត់ខ្លួននិងឆែកនៅពេលដែលសមត្ថកិច្ចប្រទះឃើញគ្រឿងញៀន និងនាំខ្លួនជនសង្ស័យទៅធ្វើការពិនិត្យទឹកនោម។ ប្រសិនបើជនសង្ស័យមានសារធាតុញៀនក៏ដាក់បទចោទប្រកាន់ឬកសាងសំណុំរឿងថា ពួកគេជាអ្នកដែលប្រើប្រាស់ និងជួញដូរគ្រឿងញៀនទាំងពីរករណីបញ្ចូលគ្នាតែម្តង។

លោក សុវណ្ណ កក្កដា បានបន្តថា ករណីដែលសមត្ថកិច្ចកសាងសំណុំរឿងបែបនេះ ពេលខ្លះប្រសិនបើជនសង្ស័យពិតជាអ្នកដែលជួញដូរមែននោះមិនអីទេ ប៉ុន្តែករណីខ្លះទៀតពួកគេមិនមែនជាអ្នកជួញដូរនោះទេ ពួកគេគ្រាន់តែជាអ្នកដែលប្រើប្រាស់ ហើយគ្រឿងញៀន ដែលត្រូវសមត្ថកិច្ចរកឃើញនោះគឺពួកគេទិញយកមកប្រើប្រាស់ខ្លួនឯង។ នៅពេលដែលសមត្ថកិច្ចកសាងសំណុំរឿងបែបនេះ ពួកគេនឹងក្លាយជាឧក្រិដ្ឋជនដោយអយុត្តិធម៌បំផុត ខណៈដែលធាតុពិតគឺពួកគេជាជនរងគ្រោះដោយសារតែគ្រឿងញៀនតែប៉ុណ្ណោះ។

លោក សុវណ្ណ កក្កដា បានបន្តថា ដូច្នេះ មុនពេលកសាងសំណុំរឿង សមត្ថកិច្ចគួរតែធ្វើការស៊ើបអង្កេតនិងសាកសួរចម្លើយឱ្យបានច្បាស់លាស់ ពីព្រោះការកសាងសំណុំរឿងដែលខ្វះការទទួលខុសត្រូវដែលអាចធ្វើឱ្យពួកគេរងនូវភាពអយុត្តិធម៌និងប៉ះពាល់ដល់អនាគតរបស់ពួកគេផងដែរ។

លោកបានបញ្ជាក់ថា៖ «ខ្ញុំមិនដឹងច្បាស់អំពីទោសទណ្ឌរវាងអ្នកជួញដូរនិងអ្នកដែលប្រើប្រាស់នោះទេ ប៉ុន្តែប្រសិនបើគេចោទប្រកាន់ថា ជួញដូរហើយនោះទោសពិតជាមិនធម្មតានោះទេ»។

លោក ជ័យ សុភ័ណ្ឌ ជាប្រជាពលរដ្ឋមួយរូបរស់នៅក្នុងខណ្ឌដូនពេញ



ជនសង្ស័យគ្រឿងញៀនមេតំហ្វេតាមីនប្រភេទទឹកកក(ICE) ទម្ងន់សុទ្ធ ១០០៤,៦៧ក្រាម។ នគរបាលជាតិ



គ្រឿងញៀនម្សៅក្រាមស ប្រភេទទឹកកកដែលសមត្ថកិចបង្ក្រាបបាននាពេលកន្លងមក។ នគរបាលជាតិ

រាជធានីភ្នំពេញក៏បានថ្លែងសំណូមពរឱ្យសមត្ថកិច្ចជំរុញការស៊ើបអង្កេតនូវបទល្មើសគ្រឿងញៀននេះឱ្យបានស៊ីជម្រៅមុនពេលដែលកសាងសំណុំរឿងបញ្ជូនទៅតុលាការផងដែរ។

លោកបានបន្តទៀតថា តាមការយល់ដឹងតាមការតាមដានព័ត៌មាន លោកបានកាត់យល់ថា របៀបដែលសមត្ថកិច្ចកសាងសំណុំរឿងបទល្មើសគ្រឿងញៀននេះ ភាគច្រើនហាក់ដូចជាមិនមានការស៊ើបអង្កេតច្បាស់លាស់នោះទេ។ រាល់ការចាប់ខ្លួនឬឃាត់ខ្លួនជនសង្ស័យគឺជាការចៃដន្យ ហើយរបៀបកសាងសំណុំរឿងគឺគ្រាន់តែយកវត្ថុតាងជាគ្រឿងញៀនដែលមាននៅលើខ្លួនជនសង្ស័យ ពិនិត្យទឹកនោម ហើយសួរចម្លើយ រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការភ្លាមៗតែម្តង។

ទាំងនេះជាយោបល់មួយជ្រុងពីពលរដ្ឋម្នាក់ពីបញ្ហាឧក្រិដ្ឋកម្មគ្រឿងញៀន និងផលប៉ះពាល់នៃការកសាងសំណុំរឿង ប្រសិនបើការកសាងសំណុំរឿងចោទប្រកាន់ជនសង្ស័យមានការខ្វះចន្លោះឬក៏ខ្វះការទទួលខុសត្រូវ។

ពលរដ្ឋមួយរូបទៀត លោក ខេង សាមេធ បានថ្លែងនូវការកត់សំគាល់របស់លោកថា បទល្មើសគ្រឿងញៀននៅពេលនេះមានច្រើនបែបច្រើនសណ្ឋានណាស់ ហើយវាត្រូវបានពួកជនខិលខូចយកមកធ្វើជាឧករណ៍រកស៊ីនិងជួញដូរព្រមទាំងរកប្រាក់បានដ៏ច្រើនសន្ធឹកសន្ធាប់។

លោក ខេង សាមេធ បានបន្ថែមទៀតថា គ្រឿងញៀននៅពេលនេះបានចាក់ឬសចាក់គល់កាន់តែជ្រៅទៅក្នុងសរសៃនៃសង្គមនៅកម្ពុជា។ មិនត្រឹមតែជនស៊ីវិលដែលជាប្រជាពលរដ្ឋមួយចំនួនទេដែលយកគ្រឿងញៀននេះធ្វើជាមុខរបរ សូម្បីតែសមត្ថកិច្ចមួយចំនួនដែលស៊ីប្រាក់ខែរដ្ឋបានមកពីការបង់ពន្ធរបស់ពលរដ្ឋនោះក៏ត្រូវបានមហាជនសង្ស័យថា បានប្រើប្រាស់គ្រឿងញៀននេះធ្វើជាមធ្យោបាយរកប្រាក់ចំណូលដែរ។

លោកបានបញ្ជាក់ថា៖ «មានចាំទេករណីដ៏កក្រើកនៅលើហ្វេសប៊ុកប៉ុន្មានខែមុន ដែលមានករណីថា មានសមត្ថកិច្ចមួយក្រុមគៀបស៊ី(យកលុយ)ពលរដ្ឋស្លូតត្រង់ដោយចោទប្រកាន់ថាជាអ្នកជួញដូរគ្រឿងញៀន ដើម្បីជាថ្នូរនឹងប្រាក់ពាន់ៗដុល្លារ ដើម្បីជាថ្នូរនឹងការលើកលែងបទចោទប្រកាន់ដែលពួកគេយកភស្តុតាងក្លែងក្លាយទៅកាឡៃថា ជនរងគ្រោះជាជនសង្ស័យជួញដូរគ្រឿងញៀននោះ»។

លោក ខេង សាមេធ បានបន្តថា រឿងនេះវាស្ងាត់ហើយ ក្រោយពេលដែលវាត្រូវបានផ្សព្វផ្សាយនិងចែករំលែកពីមួយទៅមួយរហូតដល់មេៗសមត្ថកិច្ចធំៗដាក់បទបញ្ជាតឹងរ៉ឹងឱ្យស្រាវជ្រាវមក ប៉ុន្តែសំណុំរឿងនេះក៏ដូចជាស្ងាត់ឈឹងដែរ។



ករណីជួញដូរនិងប្រើប្រាស់គ្រឿងញៀន ឃាត់ខ្លួនជនសង្ស័យ ៦នាក់។ នគរបាលជាតិ



ជនសង្ស័យនិងគ្រឿងញៀនមេតំហ្វេតាមីនចំនួន ០៤កញ្ចប់ ស្មើនឹងទម្ងន់០២ក្រាម។ នគរបាលជាតិ

ទាក់ទិននឹងបញ្ហាបទល្មើសគ្រឿងញៀននេះ មន្ត្រីនៅអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃមួយរូបបានឱ្យដឹងនៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្តសញ្ញាណថា នៅពេលនេះសំណុំរឿងបទល្មើសគ្រឿងញៀនកំពុងតែជនជោរនិងកកស្ទះ ហើយជនសង្ស័យកំពុងឃុំឃាំងនៅមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការក៏កំពុងតែមានច្រើនផងដែរ។

តាមការអះអាងរបស់មន្ត្រីនៅអគ្គនាយកដ្ឋានពន្ធនាគាររូបនោះថា ពន្ធនាគារនៅរាជធានីភ្នំពេញនិង នៅខេត្តកណ្តាលមានជនសង្ស័យច្រើនជាងគេ ឯក្រៅពីនោះ គឺនៅភូមិភាគពាយ័ព្យដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យជាដើម។

លោកបានបន្តទៀតថា ករណីការគរសំណុំរឿងគ្រឿងញៀនច្រើនបែបនេះ គឺអាចដោយសារតែសមត្ថកិច្ចមូលដ្ឋានចាប់បញ្ជូនជនសង្ស័យនៅក្រោមបទល្មើសគ្រឿងញៀនតូចៗច្រើនពេក។

ដើម្បីធានាបាននូវការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាធានី-ខេត្តពិសេសដើម្បីជួយដល់សាលាដំបូងក្រសួងយុត្តិធម៌ក្រោមការដឹកនាំរបស់លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថ្មី បានប្រកាសដាក់ចេញរួចហើយនូវយុទ្ធនាការកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ។

លោកបានមានប្រសាសន៍នៅក្នុងសន្និសីទកាសែតដោយផ្ទាល់កាលពីពាក់កណ្តាលខែឧសភាថា ការកកស្ទះសំណុំរឿងបានក្លាយជាបញ្ហាប្រឈមចំពោះមុខដែលក្រសួងយុត្តិធម៌ចាំបាច់ត្រូវជួយដល់សាលាជម្រះក្តីដើម្បីដោះស្រាយនិងចាត់ទុកការងារនេះជាផ្នែកមួយដ៏សំខាន់នៅក្នុងកម្មវិធីកំណែទម្រង់របស់ក្រសួង។

លោករដ្ឋមន្ត្រីមានបញ្ជាក់ឱ្យដឹងថា បើគិតត្រឹមថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២០ សាលាដំបូងរាជធានីនិង ខេត្តមានសំណុំរឿងព្រហ្មទណ្ឌដែលកំពុងចាត់ការសរុបចំនួន៣៩.១៥២សំណុំរឿងនៅក្នុងនោះសំណុំរឿងពាក់ព័ន្ធនឹងគ្រឿងញៀនមានចំនួនរហូតដល់ ៦.២៦០សំណុំរឿង និងមានអ្នកជាប់ឃុំសរុបចំនួន១២.៦៥១នាក់ដោយអ្នកជាប់ឃុំនៅក្នុងសំណុំរឿងគ្រឿងញៀនមានចំនួន៦.៩០០នាក់។

ជាមួយគ្នានេះ គ្រាន់តែនៅសាលាដំបូងរាជធានីភ្នំពេញ សំណុំរឿងដែលនៅសល់មិនទាន់ចាត់ការរួចកាលពីឆ្នាំ ២០១៩មានរហូតដល់១២.០០០សំណុំរឿង ហើយសំណុំរឿងដែលចូលថ្មីមានជាមធ្យមប្រមាណពី៧០០ទៅ៩០០រឿងក្នុងមួយខែដែលធ្វើឱ្យសាលាដំបូងរាជធានីភ្នំពេញក្នុងស្ថានភាពបច្ចុប្បន្នមិនអាចឆ្លើយតបដោះស្រាយបញ្ហាប្រឈមនេះបានដោយខ្លួនឯងនោះទេ។ ចំណែកសាលាដំបូងមួយចំនួនទៀតនៅតាមបណ្តាខេត្តក៏ជួបបញ្ហាប្រឈមដូចគ្នានេះដែរ ជាពិសេសខេត្តដែលមានបទល្មើសគ្រឿងញៀនច្រើនតែម្តង។ ក្នុងរយៈពេល១ឆ្នាំៗ ចៅក្រមមួយរូបបានចាត់ការសំណុំរឿងបាន១៣០រឿង។ កត្តានេះដោយសារសំណុំរឿងមានការកើនឡើងយ៉ាងកំហុក និងមានការខ្វះខាតទាំងផ្នែកធនធានមនុស្សនិងសម្ភារៈដែលធ្វើឱ្យសំណុំរឿងចាស់ៗកប់ជ្រៅទៅៗ៕

# កូនអណ្តើកហ្លួងដែលជាប្រភេទសត្វរងគ្រោះជិតផុតពូជបំផុតកំពុងមានការកើនឡើងវិញ

*ដោយ ៖ អមរិន្ទ ដានុត*



កូនអណ្តើកហ្លួងចំនួន២៣ក្បាលបានញាស់ចេញពីសំបុកចំនួន៣នៅលើឆ្នេរខ្សាច់ចំនួនពីរតាមប្រព័ន្ធព្រែកស្រែអំបិលនាដើមឆ្នាំ២០២០នេះ ដែលចំនួននេះច្រើនជាងចំនួនកូនអណ្តើកហ្លួងសរុបដែលញាស់បានក្នុងរយៈពេល៣ឆ្នាំកន្លងមក។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានឱ្យដឹងក្រុមការពារសំបុកសហគមន៍បានរកឃើញនិងបានការពារនៅលើឆ្នេរខ្សាច់ចំនួន២ទីតាំង ដែលស្ថិតនៅតាមប្រព័ន្ធព្រែកស្រែអំបិលក្នុងខេត្តកោះកុង។ សំបុកមួយក្នុងចំណោមសំបុកទាំងបីត្រូវបានរកឃើញនៅលើឆ្នេរខ្សាច់មួយដែលអណ្តើកហ្លួងធ្លាប់ពងរៀងរាល់ឆ្នាំ ចំណែកឯពីរសំបុកទៀតត្រូវបានរកឃើញនៅលើឆ្នេរខ្សាច់ថ្មីមួយតាមដងព្រែកកំពង់សោមដែលអណ្តើកហ្លួងមិនដែលមកពងកូនតាំងពីឆ្នាំ២០០៧មកម្ល៉េះ។

សំបុកអំណើកហ្លួងទាំងបីនេះមានពងសរុបចំនួន៥១ ក៏ប៉ុន្តែមានតែ២៣ពងប៉ុណ្ណោះបានញាស់ ចំណែកឯពងដែលនៅសេសសល់ខូចដោយមិនដឹងមូលហេតុ។

អង្គការ WCS បានចាត់ទុកថាជោគជ័យនេះជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងលើការងារអភិរក្សរបស់សហគមន៍មូលដ្ឋាននិងគម្រោង ហើយជាលទ្ធផលនៃការផ្សព្វផ្សាយសារាចរ និងសេចក្តីប្រកាសចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពល ដែលសម្រេចបញ្ឈប់រាល់សកម្មភាពបូមខ្សាច់នៅតាមប្រព័ន្ធព្រែកស្រែអំបិលនិងប្រកាសចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការដាក់ប្រព័ន្ធព្រែកស្រែអំបិលជាតំបន់គ្រប់គ្រងនិងអភិរក្សអណ្តើកហ្លួងនិងក្រពើត្រី។

នាយកអង្គការWCS លោក កែន សេរីរដ្ឋា បានមានប្រសាសន៍ថា កំណើននៃចំនួនកូនអណ្តើកហ្លួងនេះបង្ហាញថាក្រុមការងារអភិរក្សដែលកំពុងធ្វើការជាមួយសហគមន៍មូលដ្ឋាននិងរដ្ឋាភិបាល សម្រេចបាននូវជោគជ័យលើការការងារអភិរក្សយ៉ាងច្រើនគួរឱ្យកត់សម្គាល់។

លោកថា ដោយសារមានការគាំទ្រនិងកិច្ចសហប្រតិបត្តការជាបន្តបន្ទាប់ លោកសង្ឃឹមថាចំនួនអណ្តើកហ្លួងនឹងបន្តកើនឡើងកាន់តែច្រើននាពេលអនាគត។

លោក អ៊ុក វិបុល ប្រធាននាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា ៖ «ខ្ញុំពិតជាមានសេចក្តីរីករាយជាអនេកដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសកាលពីដើមខែមីនា ឆ្នាំ២០១៩ស្តីពីការដាក់ប្រព័ន្ធព្រែកស្រែអំបិលជាតំបន់គ្រប់គ្រងនិងអភិរក្សអណ្តើកហ្លួងនិងក្រពើត្រី។

ប្រកាសនេះនឹងមិនអនុញ្ញាតឱ្យមានការនេសាទខុសច្បាប់និងពិសេសសកម្មភាពបូមខ្សាច់នានានៅតាមប្រព័ន្ធព្រែកស្រែអំបិលមានដូចជា ព្រែកកំពង់សោម ព្រែកក្អោង និងព្រែកកំពង់លើជាដើម»។

លោកបានលើកឡើងទៀតថា រដ្ឋបាលជលផលបានធ្វើការងារយ៉ាងសកម្មជាមួយអង្គការ WCS ដើម្បីអភិរក្សអណ្តើកហ្លួងតាមរយៈសកម្មភាពការពារទីជម្រក ឆ្នេរខ្សាច់ ការស្រាវជ្រាវនិងតាមដាន កម្មវិធីការពារសំបុក ការបង្កើតសហគមន៍នេសាទនិងការងារលើកស្ទួយជីវភាពសហគមន៍នានា។

លោកស្រី ខាមីន ម៉ូរេណូ (Carmen Moreno) ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបបានលើកឡើងដែរថា កំណើននៃកូនអណ្តើកហ្លួងនេះគឺជាព័ត៌មានដ៏អស្ចារ្យសម្រាប់ប្រភេទដ៏សំខាន់ដែលកំពុងទទួលរងគ្រោះជិតផុតពូជបំផុត។

គេជឿថាអណ្តើកហ្លួងឬអណ្តើកសរសៃបានផុតពូជអស់ហើយនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែនៅឆ្នាំ២០០០ រដ្ឋបាលជលផលនិងអង្គការWCSបានរកឃើញសាជាថ្មីនូវប្រភេទអណ្តើកហ្លួងនេះមួយចំនួនតូចនៅសេសសល់តាមដងព្រែកស្រែអំបិល។

ចាប់តាំងពីពេលនោះមក អង្គការ WCS សហការជាមួយរដ្ឋបាលជលផលបានបង្កើតកម្មវិធីការពារសំបុកអណ្តើកហ្លួងនៅតាមសហគមន៍ដោយប្រើអតីតអ្នកប្រមូលពងអណ្តើកហ្លួងឱ្យចូលរួមក្នុងកម្មវិធីអភិរក្សដែលរួមមានសកម្មភាពស្វែងរកពងអណ្តើកនិងការពារសំបុកអណ្តើកចៀសជាងប្រមូលយកពងរបស់វាទៅលក់និងបរិភោគ។

អង្គការ WCS បានបន្តអនុវត្តកម្មវិធីការពារសំបុកដោយសហការជាមួយសហគមន៍នេសាទនៅក្នុងស្រុកស្រែអំបិល ខេត្តកោះកុងនិងស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងជាមួយរដ្ឋបាលជលផលចាប់តាំងពីឆ្នាំ២០០៣មក។

នាយកផ្នែកអភិរក្សនិងស្រាវជ្រាវ និងសេវាពេទ្យសត្វនៃសួនសត្វសិង្ហបូរ (Wildlife Reserves Singapore) លោកស្រីបណ្ឌិត សុនចា លូហ្ស (Dr. Sonja Luz) មានប្រសាសន៍ថា៖ «យើងមានសេចក្តីរីករាយឥតឧបមា ដោយបានឃើញលទ្ធផលវិជ្ជមាននៃកិច្ចសហការក្នុងភាពជាដៃគូក្នុងការអភិរក្សអណ្តើកហ្លួងនៅក្នុងទីជម្រកធម្មជាតិរបស់វា។ យើងទន្ទឹងរង់ចាំបន្តភាពជាដៃគូនេះជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀតដើម្បីគាំទ្រដល់ការងារអភិរក្សអណ្តើកហ្លួងដែលកំពុងទទួលរងគ្រោះថ្នាក់ជិតផុតពូជបំផុតទាំងនេះ»៕

# កំណើននៃសំបុកនិងពងកន្ទាយក្បាលកង្កែបមានចំនួនកើនឡើងជាងឆ្នាំមុន

*ដោយ ៖ ...*



នៅក្នុងរដូវពងកូនឆ្នាំ២០២០នេះ ក្រុមការពារសំបុកនៅសហគមន៍បានរកឃើញសំបុកកន្ទាយក្បាលកង្កែបចំនួន៤៩សំបុកដែលមានពងអណ្តើកចំនួន១៧៥៦ពង។ នេះបើយោងតាមរបាយការណ៍របស់អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS) ដែលបានចេញផ្សាយកាលពីថ្ងៃទី២៣ ខែឧសភា ក្នុងការអបអរសាទរទិវាអណ្តើកពិភពលោក។

ប្រភពដដែលបានឱ្យដឹងថា ទោះបីជាចំនួននេះកើនលើសឆ្នាំ២០១៩ តែពីរសំបុកក្តី ប៉ុន្តែបើគិតជាចំនួនពងសរុបប្រចាំឆ្នាំគឺមានការកើនឡើងបើធៀបនឹងបីឆ្នាំកន្លងមក។ គិតត្រឹមថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០មានកូនកន្ទាយក្បាលកង្កែបសរុបចំនួន៨២៤ កូនបានញាស់ចេញពីសំបុកចំនួន៤១សំបុកដែលក្នុងនោះកូនកន្ទាយចំនួន៦៥៧ត្រូវបានលែងចូលក្នុងទីជម្រកធម្មជាតិវិញ ចំណែកឯកូនកន្ទាយដែលនៅសល់ ក្រុមការងារកំពុងមើលថែទាំនិងគ្រោងលែងចូលទីជម្រកធម្មជាតិវិញក្នុងពេលឆាប់ៗខាងមុខនេះ។

លោក កែន សេរីរដ្ឋា នាយកអង្គការ WCS បាននិយាយក្នុងសេចក្តីប្រកាសព័ត៌មានថា ដោយមានការគាំទ្រជាបន្តបន្ទាប់ពីម្ចាស់ជំនួយរបស់យើង និងមានកិច្ចសហប្រតិបត្តិការល្អពីរដ្ឋបាលជលផល ព្រមទាំងមានការប្តេជ្ញាចិត្តខ្ពស់របស់បុគ្គលិកនៅទីវាលរបស់យើងនិងក្រុមការពារសំបុកនៅសហគមន៍ អង្គការWCS សម្រេចបាននូវសមិទ្ធិផលជាច្រើនគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តគម្រោងរបស់ខ្លួនក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។

លោក កែន សេរីរដ្ឋា បានថ្លែងបន្ថែមថា៖ «កំណើននៃសំបុកនិងពងកន្ទាយបានជំរុញនិងលើកទឹកចិត្តយើងឱ្យខិតខំប្រឹងប្រែងបន្តទៀតដើម្បីអភិរក្សកន្ទាយក្បាលកង្កែបដែលកំពុងទទួលរងគ្រោះជិតផុតពូជបំផុតនេះ»។

ប្រធាននាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផល លោក អ៊ុក វិបុល មានប្រសាសន៍ថា លោកអបអរសាទរយ៉ាងក្រៃលែងចំពោះការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ ប្រជាពលរដ្ឋ និងពិសេសអង្គការWCSដែលបាននឹងកំពុងស្តារប្រភេទដែលកំពុងរងគ្រោះថ្នាក់នេះឱ្យមានវត្តមានក្នុងដែនទឹកធម្មជាតិនេះឡើងវិញ។

លោកក៏បានស្នើឱ្យភាគីពាក់ព័ន្ធបន្តកិច្ចការស្តារប្រភេទកន្ទាយនេះ ព្រមទាំងក្រើនរំលឹកដល់ជនមួយចំនួនដែលនៅតែបន្តជួញដូរប្រភេទសត្វនេះនឹងត្រូវទទួលទោសចំពោះមុខច្បាប់។

នៅកម្ពុជាអ្នកវិទ្យាសាស្ត្រមិនបានរកឃើញវត្តមានប្រភេទកន្ទាយ នេះទេក្នុងចន្លោះពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៧ ក៏ប៉ុន្តែក្នុងឆ្នាំ២០០៧អង្គការអភិរក្សអន្តរជាតិ (CI) បានរកឃើញវត្តមានកន្ទាយនេះនៅក្នុងទន្លេមេគង្គចន្លោះពីខេត្តក្រចេះដល់ស្ទឹងត្រែង។ អង្គការអភិរក្សអន្តរជាតិ CI បានធ្វើការជាមួយរដ្ឋបាលជលផលការពារប្រភេទកន្ទាយនេះរហូតដល់ឆ្នាំ២០១៧ទើបប្រគល់គម្រោងនេះឱ្យមកអង្គការWCS គ្រប់គ្រងបន្ត។

លោកស្រីបណ្ឌិត សុនចា លូហ្ស (Dr. Sonja Luz) នាយកផ្នែកអភិរក្សនិងស្រាវជ្រាវ និងសេវាពេទ្យសត្វនៃសួនសត្វសិង្ហបូរ (Wildlife Reserves Singapore) បានមានប្រសាសន៍ថា ក្នុងនាមជាអង្គការធ្វើការងារផ្នែកអភិរក្សសត្វព្រៃ ក្រៅពីការមើលថែទាំងសត្វព្រៃនៅក្នុងសួនសត្វព្រៃរបស់យើង យើងក៏នៅតែមានភារកិច្ចនិងការទទួលខុសត្រូវជាច្រើនទៀតដែរក្នុងការការពារប្រភេទសត្វនានាដែលកំពុងទទួលរងការគំរាមកំហែងនៅក្នុងធម្មជាតិ៕





# លោក ស៊ុត ឌីណា អតីតឯកអគ្គរាជទូតកម្ពុជាប្រចាំកូរ៉េខាងត្បូង ត្រូវបានលើកលែងទោស

*ដោយ ៖ អមរិន្ទ ដានុត*

ព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានចេញព្រះរាជក្រឹត្យបង្គាប់លើកលែងទោសឱ្យទណ្ឌិត ស៊ុត ឌីណា អាយុ៤៥ឆ្នាំ ដែលត្រូវតុលាការសម្រេចផ្តន្ទាទោសជាប់ពន្ធនាគារកំណត់៥ឆ្នាំពីបទរំលោភអំណាច (បទល្មើសមានប្រសិទ្ធភាព) និងកេងយកផលប្រយោជន៍ដោយខុសច្បាប់តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថាពរចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦របស់សាលារាជធានីភ្នំពេញ។ នេះបើយោងតាមព្រះរាជក្រឹត្យដែលឡាយព្រហស្តលេខាដោយព្រះមហាក្សត្រព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០កន្លងមកនេះ។

យោងតាមលិខិតដែលបានចុះហត្ថលេខាដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កើត រិទ្ធ បានធ្វើឱ្យប្រធាននិងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃសុក្រ ទី១៥ ខែឧសភានេះចាត់វិធានការអនុវត្តតាមព្រះរាជក្រឹត្យនេះឱ្យបានសម្រេច។

លោក គុជ គឹមឡុង អ្នកនាំពាក្យសាលារាជធានីភ្នំពេញ បានបញ្ជាក់ឱ្យដឹងនៅយប់ថ្ងៃសុក្រនេះថា លោក ស៊ុត ឌីណា ដែលត្រូវបានសាលារាជធានីភ្នំពេញសម្រេចផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេល៥ឆ្នាំពីបទរំលោភអំណាចនោះពិតជាត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលើកលែងទោសហើយ។

លោក គុជ គឹមឡុង បានប្រាប់ថា៖ »ក្រោយពេលអនុវត្តទោសនិងសាលក្រមស្ថាពរនេះ លោក ស៊ុត ឌីណា ត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹតលើកលែងទោស។ ចឹង! តាមអំណាចព្រះរាជក្រឹតនេះ ទណ្ឌិតរូបនេះត្រូវបានដោះលែងតាមអំណាចព្រះរាជក្រឹត្យរួចរាល់ហើយ»។

គួរបញ្ជាក់ផងដែរថា លោក ស៊ុត ឌីណា អតីតឯកអគ្គរាជទូតកម្ពុជាប្រចាំកូរ៉េខាងត្បូងត្រូវបានបានអង្គភាពប្រឆាំងអំពើពុករលួយឃាត់ខ្លួនកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ហើយលោកត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញបានសម្រេចចេញដីកាឃុំខ្លួននៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦៕

# លទ្ធផលនៃការសំអាតគ្រាប់មិនទាន់ផ្ទុះក្នុងរយៈពេល៤ខែឆ្នាំនេះ





*បុគ្គលិកបោសសំអាតមីនរបស់ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ហៅកាត់ថា CMAC។ **រូបភាព៖ ស៊ីម៉ាក់***

*ដោយ ៖ អមរិន្ទ ដានុត*

ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២០នេះ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ហៅកាត់ថា CMAC បានបោសសម្អាតផ្ទៃដីចម្ការមីននិងចម្ការគ្រាប់បានប្រមាណជិត៣០គីឡូម៉ែត្រក្រឡា រកឃើញនិងកម្ទេចចោលសំណល់ជាតិផ្ទុះពីសង្គ្រាមគ្រប់ប្រភេទជិត១៤,០០០គ្រាប់ និងឆ្លើយតបសំណើរសុំអន្តរាគមន៍បន្ទាន់បានចំនួន១.១៨៤ករណី។

លោក ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា បានឱ្យដឹងនៅថ្ងៃចន្ទ ទី២៥ ខែឧសភា ឆ្នាំ២០២០នេះថា បើទោះបីជាជម្ងឺឆ្លងកូវីដ១៩បានគំរាមកំហែងខ្លាំងក្លាយ៉ាងណាក៏ដោយក៏ក្នុងរយៈពេល៤ខែ (មករា-មេសា ឆ្នាំ២០២០) នេះ កិច្ចប្រតិបត្តិការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមរបស់អង្គភាពស៊ីម៉ាក់បានប្រព្រឹត្តិទៅដោយរលូននិងបានទទួលលទ្ធផលគួរជាទីមោទនៈ។

លោកបានបន្តថា៖ «ជាលទ្ធផលអង្គភាពស៊ីម៉ាក់បានបោសសម្អាតផ្ទៃដីចម្ការមីននិងចម្ការ គ្រាប់បានប្រមាណជិត៣០គីឡូម៉ែត្រក្រឡា រុករកឃើញនិងកម្ទេចចោលសំណល់ជាតិផ្ទុះពីសង្គ្រាមគ្រប់ប្រភេទជិត១៤,០០០គ្រាប់ និងឆ្លើយតបសំណើរសុំអន្តរាគមន៍ បន្ទាន់បានចំនួន១.១៨៤ករណី»។

លោក ហេង រតនា បានលើកឡើងបន្ថែមថា ទន្ទឹមនឹងនេះលទ្ធផលការងារអប់រំយល់ដឹងពីមីនបានចំនួន៦.០៣០លើក មានអ្នកចូលរួមសរុប៥៣៧.៨៤៥នាក់ ហើយការស្រាវជ្រាវព័ត៌មានចំការមីន/គ្រាប់និងការងារហ្វឹកហ្វឺនក៏សំរេចបានលទ្ធផលគួរឱ្យកត់សំគាល់ផងដែរ។

លោកថា បើប្រៀបធៀបលទ្ធផលនេះជាមួយផែនការប្រចាំឆ្នាំ២០២០ ឃើញថាអង្គភាពសម្រេចបានប្រមាណ៣៥ភាគរយនៃផែនការហើយ ហើយផែនការបន្តគឺសំដៅសំរេចផែនការសរុបមានចំនួនជាង៨១គីឡូម៉ែត្រក្រឡា ដោយក្នុងនោះបើលទ្ធភាពពង្រីកកំលាំងអាចដំណើរការទាន់ពេលវេលានឹងសំរេចបាន១១២គីឡូម៉ែត្រក្រឡា៕

# សេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរ» បានចេញជារូបរាង

*ដោយ ៖ អមរិន្ទ ដានុត*

ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រុមជំនួយការរៀបចំសេចក្តីព្រាងច្បាប់ (Ad-hoc) និងក្រុមជំនួយការលេខាធិការរបស់ក្រុមការងារអន្តរក្រសួងបានប្រជុំរួមគ្នាដើម្បីពិនិត្យពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរ។

រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារនៃក្រសួងសាធារណការនិងដឹកជញ្ជូន លោក ប៉ាល់ ចន្ទតារា បានលើកឡើងថា អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកកខ្វក់ អនុក្រឹត្យ និងរចនាសម្ព័ន្ធគ្រប់គ្រងនិងដឹកនាំការងារគ្រប់គ្រងទឹកកខ្វក់នៅកម្ពុជា។

លោក ប៉ាល់ ចន្ទតារា បានគូសបញ្ជាក់ថា៖ «សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរនេះមានសារសំខាន់ណាស់ ដែលវានឹងជួយធ្វើឱ្យប្រសើរឡើងដល់ការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ធានាបាននូវសុវត្ថិភាពសុខភាពសាធារណៈនិងការអភិរក្សជីវចម្រុះ នៅពេលសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តនាពេលខាងមុខ»។

គួរកត់សម្គាល់ផងដែរថា ដោយមើលឃើញអំពីតម្រូវការកើនឡើងក្នុងការលើកកម្ពស់អនាម័យ ការគ្រប់គ្រង និងសម្អាតទឹកកខ្វក់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន បាននិងកំពុងសិក្សានិងអនុវត្តគម្រោងផ្សេងៗដែលទាក់ទងនឹងវិស័យទឹកកខ្វក់ដើម្បីលើកកម្ពស់សុខុមាលភាពនិងអនាម័យរបស់ប្រជាពលរដ្ឋ៕



*ក្រុមការងារលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរ។ **រូបភាព៖ ក្រសួងសាធារណការនិងដឹកជញ្ជូន***

# គណៈប្រតិភូព្រះសហគមន៍កាតូលិក ចូលជួបសម្តែងការគួរសមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនាថ្មី

*ដោយ ៖ លី សុវណ្ណា*

លោកអភិបាលអូលីវីយេ បានដឹកនាំគណៈប្រតិភូនៃព្រះសហគមន៍កាតូលិកបានចូលជួបសំណេះសំណាលការងារជាមួយឯកឧត្តម ឈិត សុខុន រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនាដែលទើបចូលកាន់តំណែងនាពេលថ្មីនេះ ដើម្បីជម្រាបជូននូវកិច្ចការសាសនារបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជានាព្រឹកថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ នៅទីស្តីការក្រសួងធម្មការនិងសាសនា។

ក្នុងពិធីសំណេះសំណាលនេះ លោកអភិបាល អូលីវីយេ បានជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនាអំពីរចនាសម្ព័ន្ធព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលមានសម្តេចប៉ាបជាប្រមុខដឹកនាំ ហើយក៏ជាមេដឹកនាំប្រទេសមួយដែលមានចំណងការទូតប្រមាណជា១៩០ប្រទេសលើពិភពលោក ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។


*លោកអភិបាល អូលីវីយេ ជួបសំណេះសំណាល ឯកឧត្តម ឈិត សុខុន រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនាដែលទើបចូលកាន់តំណែង។ **រូបភាព៖ ព្រះសហគមន៍កាតូលិក***

## ប្រវត្តិព្រះសហគមន៍នៅកម្ពុជា

លោកអភិបាលអូលីវីយេ បានលើកឡើងអំពីប្រវត្តិរបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលបាននាំដំណឹងល្អមកដល់ទឹកដីដ៏ល្អនេះនៅឆ្នាំ១៥៥៥ ហើយបន្តិចម្តងៗក៏មានការរីកចម្រើន។

លោកអភិបាលក៏បានជំរាបជូនរដ្ឋមន្ត្រីអំពីទីតាំងប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍កាតូលិក ដែលមានប្រមាណ២៣ទីតាំងនៅទីក្រុងភ្នំពេញដែលជាអតីតកម្មសិទ្ធិរបស់ព្រះសហគមន៍កាតូលិកពីដើម មុនសម័យសង្គ្រាមស៊ីវិលដែលមនុស្សវ័យចំណាស់ធ្លាប់រស់នៅក្នុងទីក្រុងភ្នំពេញបានស្គាល់និងចាំឈ្មោះមានដូចជា សាលាមីស សាលាដូនជីនៅជ្រោយចង្វារមានទេវវិទ្យាល័យ អារ៉ាមបងស្រីកាម៉ែល វិសាលវិហារ និងអាគារនៃសាលារាជធានីភ្នំពេញដែលជាអតីតគេហដ្ឋានរបស់លោកអភិបាលព្រះសហគមន៍ពីដើម។

លោកអភិបាលក៏បញ្ជាក់ដែរថា រាល់កម្មសិទ្ធិនិងវិហារទាំងឡាយត្រូវបំផ្លាញទាំងស្រុង សល់តែអាគារព្រះវិហារចំនួនបីកន្លែង គឺវិហារនៅបូកគោ ព្រះវិហារនៅកំពង់សោម និងវិហារតូចនៅផ្សារតូចភ្នំពេញ។

ក្រៅពីអចលនវត្ថុ ព្រះសហគមន៍ក៏បាត់បង់នូវធនធានមនុស្សជាច្រើន ដោយរួមទាំងលោកអភិបាលជាតិខ្មែរមួយរូបដំបូងគេផង គឺលោកអភិបាល ថ្នារ សាឡាស់ ដែលទទួលអគ្គសញ្ញាតែងតាំងក្នុងឆ្នាំនៃការផ្ទុះសង្គ្រាម។

លោកអភិបាលបន្តថា៖ «ឆ្នាំ៧៥ យើងបាត់បង់ទាំងអស់។ យើងត្រឡប់មកវិញនៅឆ្នាំ៩០។ នៅឆ្នាំ៧៥ ថ្ងៃទី ១៤ ខែមេសា បានតែងតាំងលោកអភិបាលខ្មែរទី១ ឈ្មោះថ្នារ សាឡាស់។ ក្រោយមកជនបរទេសត្រូវបានគេបណ្តេញចេញពីប្រទេសកម្ពុជា ប៉ុន្តែលោក ថ្នារ សាឡាស់ ជាមួយបងប្អូនគាត់ដែលជាបូជាចារ្យខ្លះដែរ ត្រូវបានជម្លៀសទៅដល់តាំងគោក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ នៅឆ្នាំ៧៧ គាត់បានស្លាប់ ដូច្នេះយើងអត់មានអ្នកដឹកនាំសាសនានៅក្នុងប្រទេសកម្ពុជាពីឆ្នាំ៧៧ រហូតដល់ឆ្នាំ៩០។ ឆ្នាំ៩០ សាសនទូតចាស់បានត្រឡប់មកវិញមួយចំនួន ដូចជាលោកអភិបាលពីដើម គឺអភិបាលអ៉ីវ៉ាមូស»។

លោកអភិបាលបានលើកបង្ហាញជូនរដ្ឋមន្ត្រីនូវឈើឆ្កាងលោកអភិបាល ដោយបញ្ជាក់ថា ឈើឆ្កាងនេះ មានអាយុជាង១០០ឆ្នាំ ជាឈើឆ្កាងលោកអភិបាលភ្នំពេញក្នុងឆ្នាំ១៩០០ ហើយត្រូវបានបញ្ជូនបន្តរហូតដល់លោកជាអភិបាលសព្វថ្ងៃ ដែលជាអភិបាលជំនាន់ទី២៤នៃភូមិភាគភ្នំពេញ។

លោកអភិបាលបានរំលឹកថា នៅពេលលោក ថ្នារ សាឡាស់ តែងតាំងជាអភិបាល បានទទួលឈើឆ្កាងនេះ ហើយម្តាយរបស់គាត់បានលាក់ឈើឆ្កាងនេះនៅក្នុងសំបុកមាន់ កុំឱ្យខ្មែរក្រហមរកឃើញ។ ដូច្នេះ ឈើឆ្កាងនេះជាវត្ថុប្រវត្តិសាស្ត្រនិងបានឆ្លងសតវត្សនិងឆ្លងសម័យខ្មែរក្រហម។

## បច្ចុប្បន្នភាពរបស់ព្រះសហគមន៍

ក្រោយសង្គ្រាមស៊ីវិលបញ្ចប់ សាសនទូតបានវិលមកកម្ពុជាវិញ ហើយនៅឆ្នាំ១៩៩៣ បានទិញដីព្រះវិហារនៅផ្សារតូច ដែលពីដើមជាអនុទេវវិទ្យាល័យ។ លោកអភិបាលអូលីវីយេក៏បញ្ជាក់ប្រាប់រដ្ឋមន្ត្រីដែរថា នៅឆ្នាំ២០១០ ក្នុងនាមជាលោកអភិបាល លោកបានទិញដីសម្រាប់ព្រះសហគមន៍កាតូលិកនៅភ្នំពេញថ្មី ដែលជាទីតាំងសកម្មមួយនិងជាកន្លែងរស់នៅ និងធ្វើការងាររបស់លោកអភិបាលផ្ទាល់។ ព្រះសហគមន៍កាតូលិកបានចាប់ផ្តើមរីកចម្រើនបន្តិចម្តងៗ។

លោកមានប្រសាសន៍ទៀតថា៖ «ឆ្នាំ២០០២ ខ្ញុំនៅតាកែវ ដូច្នេះនៅតាកែវបានចាប់ផ្តើមច្រើនក្នុងវិស័យអប់រំសិក្សា មានដូចជា វិទ្យាស្ថានសន្តប៉ូល សាលាផ្សេងៗ និងសកម្មភាពអភិវឌ្ឍច្រើនប្រហែលឯកឧត្តមធ្លាប់ឃើញ។ នៅឆ្នាំ២០០២ ខ្ញុំជិតស្និទ្ធិមែនទែនជាមួយឯកឧត្តម ចាន់ សារ៉ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម។ ឯកឧត្តមបានដើរជាមួយខ្ញុំ បានជម្រុញខ្ញុំ បានលើកទឹកចិត្តខ្ញុំ បានណែនាំឱ្យយើងបានជោគជ័យកម្មវិធីកសិកម្មផង សាលាឯកទេសផង វិទ្យាស្ថានផង រហូតដល់ខ្ញុំបានចូលសញ្ជាតិខ្មែរនៅឆ្នាំ២០១០ តាមរយៈឯកឧត្តម ចាន់ សារ៉ុន»។



សម្រាប់កិច្ចការសង្គមផ្សេងទៀត លោកអភិបាលភូមិភាគភ្នំពេញ ក៏បានលើកឡើងពីសម្ព័ន្ធអង្គការកាតូលិកចំនួន២៧ ក្នុងនោះមានអង្គការការីតាសកម្ពុជាផងដែរ ដែលកំពុងបំពេញមុខងារយ៉ាងសកម្មបម្រើប្រជាពលរដ្ឋកម្ពុជាក្នុងវិស័យសិក្សា អភិវឌ្ឍន៍ជនបទ កសិកម្ម និងសង្គមកិច្ចជាដើម។ ជាមួយគ្នានេះ ព្រះសហគមន៍បានខិតខំកសាងកិច្ចសន្ទនាបែបអន្តរសាសនាជាមួយសាសនាទាំងបីយ៉ាងសកម្ម ដើម្បីសុខដុមនីយកម្មសាសនានិងសាសនានៅកម្ពុជា។

> សាសនាទាំងអស់ត្រូវរស់នៅដោយសុខដុមនីយកម្ម មានន័យថាមានទាំងអស់គ្នា ហើយឲ្យសុខសប្បាយ កុំឲ្យមានទុក្ខ កុំឲ្យមានភ័យមានរឿង

## សកម្មភាពរបស់ព្រះសហគមន៍ក្នុងសង្គមនិងកិច្ចការសាសនាក្នុងអំឡុងពេលកូវីដ១៩

ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានចូលរួមប្រយុទ្ធនឹងជំងឺកូវីដ១៩ រួមជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយគោរពតាមការណែនាំនានារបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ក្រសួងអប់រំ និងក្រសួងធម្មការជាដើម។

លោកអភិបាលបានបន្ថែមថា ចាប់តាំងពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ព្រះសហគមន៍ផ្អាកដំណើរការសាលារៀនដោយបង្កើតកម្មវិធីរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់កម្មវិធីសិក្សាគ្រប់កំរិត។ ពិធីសាសនាក៏ត្រូវផ្អាក ទោះបីចំពេលបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាបុណ្យធំសំខាន់បំផុតសម្រាប់ព្រះសហគមន៍កាតូលិកក៏ដោយ ប៉ុន្តែយើងប្រារព្ធតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។

ទោះជាយ៉ាងនេះក្តី លោកអភិបាលជម្រាបថា៖ «គឺមិនស្រួលឡើយ យើងបានពិបាក ប៉ុន្តែយើងបានតស៊ូមែនទែន។ យើងផ្សាយផ្ទាល់ (LIVE) អភិបូជាសូត្រធម៌ យើងធ្វើសរុបរហូតដល់សព្វថ្ងៃចំនួន៦៩កម្មវិធីតាមការ LIVE តាមអ៊ីនធឺណិត តាមYOU-TUBE, FACEBOOK ប៉ុន្តែនេះក៏ពិបាកដែរ»។

លោកបញ្ជាក់ថា គេមើលតាមផ្ទះ ជួនកាលគេមើល ជួនកាលមិនមើល យាយតាដែលអត់មានអ៊ីធឺណិត។ លោកបានឱ្យដឹងថា៖ «ខ្ញុំមានមួយចំនួនទោះបីខ្ញុំផ្ញើឯកសារក៏ដោយក៏អត់ចេះអានទេ អត់ចេះអានគម្ពីរ»។ លោកបានសម្តែងក្តីបារម្ភទៀតថា គ្រីស្តបរិស័ទកាតូលិក ជាគ្រីស្តបរិស័ទជំនាន់ទី១អត់មានឫសជ្រៅនៅក្នុងជំនឿផ្ទាល់ខ្លួន។

## ក្នុងអំឡុងពេលកូវីដ១៩ តើព្រះសហគមន៍អាចជួបជុំលក្ខណៈក្រុមតូចៗបានទេ?

ទាក់ទងនឹងក្តីបារម្ភខាងលើ លោកអភិបាលបានលើកពីប្រសាសន៍របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីដែលបានអនុញ្ញាតឱ្យមានការជួបជុំតែមិនមែនលក្ខណៈធំ។ «ខ្ញុំចង់សួរឯកឧត្តម តើយើងអាចជួបជុំគ្នាខ្លះៗជាក្រុមតូច ដើម្បីថ្វាយបង្គំ ជាថ្ងៃសីលរបស់យើង កុំឱ្យយើងបាត់បង់។ ដោយសារអត់ដឹងមានគំនិតបើកសាលាសាសនាវិញនៅពេលណា? ប្រហែលយូរខែទៀត និងយើងខ្លាចគ្រីស្តបរិស័ទ ដូចជាស្ងិតរីងដូចសព្វថ្ងៃដូចបឹងស្ទឹងចាប់ផ្តើមរីងនៅកំពង់ធំ។ ខ្ញុំខ្លាចគ្រីស្តបរិស័ទរបស់ខ្ញុំជីវិតខាងផ្លូវវិញ្ញាណវាស្ងិតទៅៗនិងអស់រលីងហើយ ដោយសារតាមអ៊ីធឺណិតវាអត់សូវស្រួលទេ។ ដូច្នេះប្រសិនបើខ្ញុំអាចរៀបចំជាក្រុមតូចៗ មិននិយាយអ៊ីជាផ្លូវការមហាកំពូល ប៉ុន្តែគ្រាន់តែនិយាយខ្លះៗជាព្រះសហគមន៍អាចទៅមុខកុំឱ្យដាច់ៗអុកស៊ីសែន។ ឯកឧត្តមយល់យ៉ាងណាដែរ?»។

ជាការឆ្លើយតប ឯកឧត្តម ឈិត សុខុន បានបញ្ជាក់ថា៖ «សុខាភិបាលគេប្រាប់ថា កុំឱ្យយើងជួបជុំគ្នាក្នុងបុណ្យធំ ហើយរក្សាគម្លាត។ ពេលជួបជុំគឺក្រុមធំមានគ្នាច្រើន មិនអាចរក្សាគម្លាតបាន ១ម៉ែត្រកន្លះទៅ២ម៉ែត្របានទេ ទោះបីសាលធំយ៉ាងម៉េចក៏ដោយ។ បើធ្វើខុសពីហ្នឹង បើមានបញ្ហានោះមិនបានទេ វាមិនស្ងិតទេគឺស្លាប់តែម្តង។ បើគ្រាន់តែស្ងិត ស្រោចទឹកឡើងវិញ គឺលាស់ឡើងវិញស្រស់។ តែបើស្លាប់មិនលាស់ទេ»។

រួមជាមួយគ្នានេះដែរ លោករដ្ឋមន្ត្រីក៏បានលើកឡើងអំពីរដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់កម្ពុជាដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទាំងអស់មានសិទ្ធិជឿលើសាសនាអ្វីក៏បាន ហើយក៏បានរំលឹកអំពីការរក្សាសុខដុមនីកម្មសាសនានិងសាសនា ដែលជាទិសដៅរបស់រដ្ឋាភិបាលក្នុងយុទ្ធសាស្ត្រចតុកោណផងដែរ ដើម្បីឱ្យប្រទេសជាតិមានសុខសន្តិភាព។ លោករដ្ឋមន្ត្រីមានប្រសាសន៍ថា៖ «សាសនាទាំងអស់ត្រូវរស់នៅដោយសុខដុមនីយកម្ម មានន័យថាមានទាំងអស់គ្នា ហើយឱ្យសុខសប្បាយ កុំឱ្យមានទុក្ខ កុំឱ្យមានភ័យមានរឿង»។

លោករដ្ឋមន្ត្រីមានប្រសាសន៍ទៀតថា៖ «សូមថ្លែងអំណរគុណណាស់ចំពោះប្រតិភូព្រះសហគមន៍កាតូលិកដឹកនាំដោយលោកអភិបាលអូលីវិយេដែលអញ្ជើញមកក្រសួងធម្មការនិងសាសនានេះ! សំខាន់ជួយដល់ប្រជាពលរដ្ឋទាំងអស់ដែលកំពុងរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩នេះ។ អំណោយរបស់លោកនៅពេលនេះគឺមានសារៈសំខាន់ណាស់ សម្រាប់អាយុជីវិត របស់ប្រជាពលរដ្ឋ។ យើងខ្ញុំនឹងខិតខំយកអំណោយទាំងនេះទៅចែកចាយដល់បងប្អូន»។

ក្នុងដំណើរជួបសំណេះសំណាលនេះ ព្រះសហគមន៍ដែលមានអង្គការការីតាសកម្ពុជាក៏បានជូនសម្ភារៈអនាម័យដល់ក្រសួងធម្មការនិងសាសនា មានផ្ទាំងផ្សព្វផ្សាយប្រឆាំងកូវីដចំនួន ៦០០សន្លឹក ម៉ាស់ការពារ ២០០ប្រអប់ សាប៊ូ២០០០ដុំ និងទឹកអាល់កុលចំនួន២០០លីត។ ជាមួយគ្នានេះដែរ លោកអភិបាលក្នុងនាមព្រះសហគមន៍កាតូលិកបានចូលរួមវិភាគទាននូវថវិកាចំនួន១០០០ដុល្លារផងដែរ៕


*លោកអភិបាល អូលីវីយេ និងឯកឧត្តម ឈិត សុខុន។ **រូបភាព៖ ព្រះសហគមន៍កាតូលិក***



ក្រុមដូនជីក្នុងក្រុមគ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ។ **រូបភាព៖ ព្រះសហគមន៍កាតូលិក**



លោកប៊្រុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។ **ព្រះសហគមន៍កាតូលិក**

# ដូនជីពីររូបក្នុងក្រុមគ្រួសារស្រឡាញ់ ឈើឆ្កាងព្រះយេស៊ូសច្ចាលើកទី២

*ដោយ ៖ កែវ កញ្ញា*

បងស្រី ពេន ហ៊ីល និងបងស្រី ចាន់ រដ្ឋា ជាដូនជីក្នុងក្រុមគ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ បានបន្តពាក្យសច្ចារបស់ខ្លួននៅក្នុងក្រុមគ្រួសារនេះជាលើកទី២ ដើម្បីបន្តបេសកកម្មជាអ្នកបួសបម្រើព្រះសហគមន៍កាតូលិកក្នុងភូមិភាគកំពង់ចាមរយៈពេលមួយឆ្នាំទៀត ក្រោមអធិបតីភាពលោកប៊្រុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម រួមនឹងវត្តមានលោកបូជាចារ្យមួយចំនួន និងបងស្រីក្នុងក្រុមគ្រួសារកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០នេះ នៅព្រះវិហារកំពង់ចាមក្រុង។

នៅក្នុងធម្មទេសនា លោកអភិបាល ប៊្រុយណូ កូសម៍ បានមានប្រសាសន៍ថា ព្រះជាម្ចាស់បានបង្កើតយើង ដូច្នេះសូមឱ្យយើងចេះទទួលអំណោយទានរបស់ព្រះអង្គ ប៉ុន្តែលោកីយ៍នេះហាក់មិនព្រមទទួលព្រះបន្ទូលនិងប្រហែលមិនយល់អំពីព្រះបន្ទូល ប៉ុន្តែអ្វីដែលសំខាន់ជាងគេគឺឱ្យយើងជាបូជាចារ្យ និងបងស្រី មានសមត្ថភាពទទួលព្រះបន្ទូល។

លោកអភិបាលបានរំលឹកអំពីឃ្លាគម្ពីរកិច្ចការគ្រីស្តទូតថា៖ «"បើឱ្យនោះនឹងមានសុភមង្គលច្រើនជាងទទួល" ។ មានន័យថា អ្វីដែលយើងទទួលគឺមិនមែនឱ្យយើងទុកតែឱ្យយើងចែក។ នេះជាមរតកដែលជួយយើងសហការជាមួយព្រះជាម្ចាស់ដែលកំពុងកសាងព្រះសហគមន៍។ អ្វីដែលយើងបានទទួល គឺសម្រាប់ព្រះជាម្ចាស់ សម្រាប់បងប្អូនយើង ដើម្បីជួយកសាងព្រះសហគមន៍»។

លោកអភិបាលបានបន្ថែមថា៖ «ថ្ងៃនេះយើងរំលឹកអំពីពាក្យសច្ចារបស់បងស្រីនិងពាក្យសន្យារបស់យើង (បូជាចារ្យ) ជាអ្វីដែលបង្ហាញពីអត្តសញ្ញាណរបស់យើង បេសកកម្មដែលយើងទទួលពីព្រះជាម្ចាស់ ទទួលពីព្រះសហគមន៍ ហើយយើងនៅតែបន្តកសាងព្រះសហគមន៍ជាមួយព្រះជាម្ចាស់»។

បងស្រី ពេន ហ៊ីល ជាបេក្ខជនប្រកាសពាក្យសច្ចាប្រណិធានបានប្រាប់ថា ក្នុងរយៈពេលពីរឆ្នាំមកនេះ បងស្រីបានទៅបម្រើព្រះសហគមន៍នៅខេត្តស្ទឹងត្រែង។ នៅទីនោះ បងស្រី ហ៊ីល បានចុះទៅតាមភូមិអ្នកស្រុក ដើម្បីអប់រំកុមារតូចៗអំពីអនាម័យ ចុះសួរសុខទុក្ខចាស់ជរា អប់រំជំនឿដល់អ្នកឈ្វេងយល់ជាដើម។

ទោះបីក្នុងអំណរសប្បាយនៃកិច្ចការបម្រើ ប៉ុន្តែក្នុងជីវិតក៏មាននូវឧបសគ្គមួយចំនួនដែរ។ ដូនជីរូបនេះបន្ថែមថា ក្នុងកាលៈទេសៈដែលធ្លាក់ទឹកចិត្តខ្លាំងគឺនៅពេលដែលឪពុកម្ដាយជួបការលំបាកនិងបងស្រីផ្ទាល់មានជំងឺ ជាពេលវេលាដែលអស់សង្ឃឹម និងចង់លះបង់កិច្ចការបម្រើរបស់ព្រះជាម្ចាស់។

និយាយទាំងអួលដើមក បងស្រី ហ៊ីល ឱ្យដឹងថា៖ «ពេលនោះ... វាពិបាកមែនទែន។ ខ្ញុំរកលោក (បូជាចារ្យ) ជួយនិងស្រាយបាបដែរ។ ប៉ុន្តែមិនអាចជួយបាន តែអ្វីដែលជួយខ្ញុំបាន ខ្ញុំសុំទោសព្រះជាម្ចាស់»។

> ទោះបីយើងជ្រើសរើសយកមួយណាក៏ដោយ បើយើងមានសេចក្ដីស្រឡាញ់ពិត ជម្រើសរបស់យើងមិនខុសទេ។ កុំឲ្យខ្លួនឯងបិទបេះដូងមិនហ៊ានទទួល ខ្លាចបរិយាកាសជុំវិញខ្លួន។ កុំខ្លាច! បើព្រះជាម្ចាស់ត្រាស់ហៅហើយសូមទៅ។ ពេលទៅ ព្រះជាម្ចាស់នឹងត្រួសត្រាយផ្លូវឲ្យ ហើយអំណរសប្បាយនោះនឹងមាន

បងស្រីបន្ថែមថា៖ «អ្វីៗទាំងអស់ជាការបន្ទុទ្ធរបស់ព្រះអង្គ ដើម្បីឱ្យខ្ញុំទៅជាមនុស្សដ៏វិសុទ្ធ»។ បងស្រីបានបញ្ជាក់ទៀតថា គ្មានអ្វីដែលល្អជាងការដាក់ខ្លួនដើម្បីស្គាល់ព្រះជាម្ចាស់ រាល់ជំងឺដែលមាននៅក្នុងដួងចិត្ត ជំនួសដោយការអធិដ្ឋានដោយពិតប្រាកដដែលនាំឱ្យគាត់ទទួលដឹងថា «ព្រះជាម្ចាស់យាងមករកខ្ញុំមែន»។

បទពិសោធន៍នៅក្នុងជីវិតដែលអស់សង្ឃឹមនោះ បានធ្វើឱ្យរូបបងស្រី ហ៊ីល ផ្ទាល់ មានជំនឿកាន់តែខ្លាំងថែមទៀត។ បងស្រី ហ៊ីល ថា៖ «ខ្ញុំឈឺខ្លាំងមែនទែន ខ្ញុំអធិដ្ឋាន ខ្ញុំឃើញដូចមានខ្យល់មួយស្ទាបនៅខ្នងខ្ញុំ។ ពេលនោះ ខ្ញុំក្រាបនៅមុខព្រះពន្លា ថ្ងៃនោះដូចជាព្រះជាម្ចាស់មកស្ទាប លួងលោមខ្ញុំ។ ខ្ញុំស្រាប់តែបាត់ការឈឺចាប់ទាំងនោះ»។

ជាមួយគ្នានេះដែរ បងស្រី ចាន់ រដ្ឋា ដែលកំពុងបម្រើការងារនៅខេត្តព្រៃវែង បានរៀបរាប់ដែរថា ក្នុងរយៈពេល២ឆ្នាំមកនេះ គាត់ទទួលបានអំណរសប្បាយណាស់។ «ខ្ញុំតាំងពីចូលបួស រហូតមកដល់ឥឡូវ ខ្ញុំមិនដែលគិតថាចង់ចេញ ហើយរាល់ឧបសគ្គដែលមានគឺរឿងតូចៗ ជាពិសេសក្នុងការងារមិនសូវមានអីប៉ុន្មានទេ ពីព្រោះធ្វើការងារ



បងស្រី ពេន ហ៊ីល និងបងស្រី ចាន់ រដ្ឋា ជាដូនជីក្នុងក្រុមគ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ បានបន្តពាក្យសច្ចារបស់ខ្លួន។ **ព្រះសហគមន៍កាតូលិក**

ជាមួយបងស្រី (ដូនជី) និងលោកពុក (បូជាចារ្យ) គាត់ស្រឡាញ់ គាត់អាណិត គាត់យល់»។

ទោះយ៉ាងណា បងស្រីក៏ទទួលនូវការល្បួងខ្លះៗដែរ ប៉ុន្តែការទាំងនោះកើតឡើងតែមួយភ្លែតប៉ុណ្ណោះចំពោះរូបគាត់។ ដូនជីរូបនេះឱ្យដឹងថា៖ «សញ្ញាតិជាមនុស្សស្រី យើងមានបេះដូង ជួនកាលខ្ញុំមានអារម្មណ៍ថា ប្រសិនបើខ្ញុំមានគ្រួសារយ៉ាងម៉េច? វាជាអារម្មណ៍មួយភ្លែត ប៉ុន្តែសំខាន់អារម្មណ៍ខ្លាំងបំផុតគឺស្រឡាញ់ព្រះសហគមន៍។ ព្រះសហគមន៍មានអំណរ ខ្ញុំមានអំណរ ព្រះសហគមន៍យំ ខ្ញុំយំជាមួយព្រះសហគមន៍»។

បងស្រីរដ្ឋា បានជំរុញឱ្យយុវជនកាតូលិកទាំងអស់ហ៊ានជ្រើសរើសជីវិតដើរតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ ជាជាងដើរតាមលោកីយ៍។ បងស្រីរដ្ឋាបានលើកឡើងថា៖ «ទោះបីយើងជ្រើសរើសយកមួយណាក៏ដោយ បើយើងមានសេចក្ដីស្រឡាញ់ពិត ជម្រើសរបស់យើងមិនខុសទេ។ កុំឱ្យខ្លួនឯងបិទបេះដូងមិនហ៊ានទទួល ខ្លាចបរិយាកាសជុំវិញខ្លួន។ កុំខ្លាច! បើព្រះជាម្ចាស់ត្រាស់ហៅហើយ សូមទៅ។ ពេលទៅ ព្រះជាម្ចាស់នឹងត្រួសត្រាយផ្លូវឱ្យ ហើយអំណរសប្បាយនោះនឹងមាន»។

ក្នុងកម្មវិធីប្រកាសពាក្យសច្ចាប្រណិធានលើកទី២នេះ របស់បងស្រី ពេន ហ៊ីល និងបងស្រីចាន់ រដ្ឋា ក្រុមបងស្រីស្រឡាញ់ឈើឆ្កាងបួននាក់ផ្សេងទៀតដែលបានធ្វើពាក្យសច្ចានិរន្តក៏បានរំលឹកអំពីភក្តីភាពចំពោះព្រះជាម្ចាស់ក្នុងកិច្ចការបម្រើព្រះសហគមន៍ផងដែរ។ រួមជាមួយគ្នានេះ លោកបូជាចារ្យដែលបានបម្រើការក្នុងភូមិភាគកំពង់ចាមបានធ្វើការរំលឹកនូវពាក្យសន្យារបស់ខ្លួនឡើងវិញផងដែរនៅចំពោះមុខលោកអភិបាលគ្រប់គ្រងរបស់ភូមិភាគដែលនេះជាកម្មវិធីលើកទី១ក្នុងប្រវត្តិសាស្ត្រនៃព្រះសហគមន៍។

ជាទូទៅ ជារៀងរាល់មួយឆ្នាំម្តងនៅថ្ងៃបុណ្យប្រសិទ្ធពរលើប្រេងគ្រីស្មា ដែលធ្វើឡើងមុនបុណ្យចម្លង លោកបូជាចារ្យដែលបម្រើការងារនៅក្នុងប្រទេសកម្ពុជាទាំងអស់ បានជួបជុំគ្នាប្រារព្ធពិធីនេះ និងជាឱកាសនៃការរំលឹកពាក្យសន្យារបស់ខ្លួនឡើងវិញផងដែរ ប៉ុន្តែដោយសារឆ្នាំនេះក្នុងវិធានការការពារនិងបង្ការកូវីដ១៩ ព្រះសហគមន៍មិនអាចជួបជុំគ្នាជាលក្ខណៈធំបាន ទើបធ្វើដាច់ដោយឡែកតាមភូមិភាគនីមួយៗ៕





# ព្រះសហគមន៍កាតូលិក រួមសាមគ្គីភាព ជាមួយសាសនានានាប្រឆាំងកូវីដ១៩

*ដោយ ៖ ដាលីស*

ព្រះសហគមន៍កាតូលិក ដែលមានអង្គការការីតាសកម្ពុជា ជាសេនាធិការបម្រើកិច្ចមនុស្សធម៌នៅកម្ពុជា នាព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ បាននាំយកសម្ភារៈអនាម័យត្រៀមបង្ការនិងប្រឆាំងមេរោគកូវីដ១៩ ថ្វាយសម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃប្រទេសកម្ពុជា ប្រគេនជូនព្រះសកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា។





(ឆ្វេង) សម្ភារៈអនាម័យត្រៀមបង្ការនិងប្រឆាំងមេរោគកូវីដ១៩ បានប្រគេនថ្វាយសម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃប្រទេសកម្ពុជា និងប្រគេនជូនព្រះសកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។ **រូបភាព៖ ព្រះសហគមន៍កាតូលិក**

លោកបូជាចារ្យនៃព្រះសហគមន៍កាតូលិក សួន ហង្សលី ដែលជាតំណាងពេញសិទ្ធិរបស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយបុគ្គលិករបស់អង្គការការីតាសកម្ពុជា បាននាំយកសម្ភារៈទាំងនេះថ្វាយប្រគេន និងជូននៅទីតាំងផ្សេងៗពីគ្នា មាននៅវត្តបុទុមវតី (សម្រាប់គណៈធម្មយុត្តិកនិកាយ) ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងនៅទីតាំងគីឡូម៉ែត្រលេខ៩។



សម្ភារៈអនាម័យក៏បានផ្តល់ជូនគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សម្រាប់ប្រើប្រាស់បង្ការនិងប្រឆាំងមេរោគកូវីដ១៩។ **រូបភាព៖ ព្រះសហគមន៍កាតូលិក**

លោកបូជាចារ្យ សួន ហង្សលី បានប្រសាសន៍ថា៖ «ការថ្វាយ ប្រគេន និងចែកជូនបរិក្ខារអនាម័យទាំងនេះដើម្បីបង្ហាញសាមគ្គីភាពរវាងសាសនានិងសាសនានៅក្នុងប្រទេសកម្ពុជា និងការចូលរួមជាមួយរដ្ឋាភិបាលក្នុងការទប់ស្កាត់ ការឆ្លងរីករាលដាលមេរោគកូវីណាដែលគ្រប់គ្នាកំពុងភ័យខ្លាច ហើយដែលអាចកើតរលកទី២ដែលនាំឱ្យមានគ្រោះថ្នាក់ច្រើនជាងនេះទៀត»។

លោកបូជាចារ្យរូបនេះបានលើកឡើងទៀតថា ពិតមែនបញ្ហាកូវីដ១៩ធ្វើឱ្យមានការលំបាក ព្រះសហគមន៍មិនមានសកម្មភាពសាសនាឱ្យបានកាន់តែទូលំទូលាយ ក៏ប៉ុន្តែនេះជាឱកាសមួយល្អដើម្បីចែករំលែកសេចក្តីស្រឡាញ់និងជំនឿពីព្រះជាម្ចាស់។

លោកបូជាចារ្យ សួន ហង្សរី ក៏បានថ្លែងអរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានអនុញ្ញាតឱ្យមានការគោរពប្រណិបត្តិសាសនាទៅតាមជំនឿរៀងៗខ្លួននៅទូទាំងប្រទេសកម្ពុជា។ ទោះបីជាមានសាសនាផ្សេងៗពីគ្នា ប៉ុន្តែគ្រប់គ្នាចេះសាមគ្គីគ្នា ដើម្បីស្វែងរកសេចក្តីសុខនៅកម្ពុជា។

លោក សឹម ម៉ាត់ទោត តំណាងថ្នាក់ដឹកនាំឥស្លាមសាសនិក បានមានប្រសាសន៍នាឱកាសនោះដោយថ្លែងអំណរគុណដល់អង្គការការីតាសកម្ពុជា និងព្រះសហគមន៍កាតូលិកដែលបានមកសួរសុខទុក្ខ ព្រមទាំងនាំមកជាមួយនឹងសម្ភារៈអនាម័យមួយចំនួនដូចជាសាប៊ូ ទឹកអាល់កុល និងម៉ាស់ជាដើម។

លោកបានបញ្ជាក់ថា៖ «ឥស្លាមសាសនា និងគ្រីស្តសាសនា តាំងពីដើមមកយើងមានជំនឿលើព្រះជាម្ចាស់តែមួយ ជាបងប្អូនគ្នា»។

ជាមួយគ្នានេះដែរ សម្តេចព្រះមហាអរិយវង្ស បណ្ឌិត ឃី សុវណ្ណរតនា ជាសាកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដែលមានបន្ទុកដឹកនាំទាំងស្រុងនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ្យ បានមានសង្ឃដីការអរគុណដល់ព្រះសហគមន៍កាតូលិក និងអង្គការការីតាសកម្ពុជា ដែលបានឧបត្ថម្ភសម្ភារៈអនាម័យ ដែលជាផ្នែកមួយនៃការរស់នៅស្អាត។ សម្តេចក៏បានលើកទឹកចិត្តប្រជាពលរដ្ឋទាំងអស់ត្រូវរស់នៅស្អាត និងថែរក្សាបរិស្ថាន ព្រោះមិនមែនត្រឹមតែបង្ការវីរុសកូវីដ១៩នេះទេ តែក៏នាំមកនូវសុខភាពល្អ រឹងមាំ មិនពិបាកដល់គ្រួសារនិងសហគមន៍។

សម្តេចមានសង្ឃដីការបន្ថែមថា ព្រះពុទ្ធសាសនា តែងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយអន្តរសាសនា និងមានសក្ខីភាព ដោយបានធ្វើការច្រើនជាមួយអង្គការអន្តរសាសនាទាំងគ្រីស្តសាសនា និងឥស្លាមសាសនា ហើយបានចូលរួមជាមួយគ្នាតាមរយៈកម្មវិធីជាច្រើននាពេលកន្លងមកផងដែរ។

ជាចុងក្រោយនៃដំណើរសួរសុខទុក្ខនេះ ក្រុមប្រតិភូអង្គការការីតាសបានចូលបង្គំថ្វាយសម្ភារៈអនាម័យចំពោះសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី ក្នុងវត្តបុទុមវតី។ សម្តេចព្រះសង្ឃរាជបានមានសង្ឃដីកាឱ្យគ្រប់បរិស័ទនៃគ្រប់សាសនា ចេះរួបរួមគ្នា។

សម្តេចព្រះសង្ឃរាជ បួរ គ្រី មានថេរដីកាថា៖ «មិនថាអ្នកកាន់សាសនាណាក៏ដោយ នៅលើទឹកដីខ្មែរដូចគ្នា ត្រូវចេះរួបរួមគ្នាកុំប្រកាន់សាសនា។ ត្រូវរក្សាអនាម័យកុំឱ្យភ្លេចខ្លួន ព្រោះថាជំងឺកូវីតនេះមិនរើសសាសនានោះទេ»។

ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសផ្អាកការជួបជុំនានាបែបសាសនាទាំងអស់នៅទូទាំងប្រទេស។

គួរបញ្ជាក់ថាសម្ភារៈអនាម័យដែលបានយកទៅថ្វាយ ប្រគេន និងជូនតាមកន្លែងនីមួយៗ មាន សាប៊ូ២០១៦ដុំ ម៉ាសចំនួន១០០ប្រអប់ អាល់កុលចំនួន ៨០លីត្រ និងផ្ទាំងផ្សព្វផ្សាយចំនួន ៤០០ផ្ទាំង៕

# ព្រះសហគមន៍កាតូលិកនិងវត្ត ព្រះពុទ្ធសាសនាដាំបន្លែសរីរាង្គរួមគ្នា

*ដោយ ៖ ព្រះសហគមន៍*

រោងបន្លែសរីរាង្គមួយដែលត្រូវបានសាងសង់ឡើងដោយព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹម (ចម្ការទៀង) បានប្រគេនព្រះសង្ឃក្នុងវត្តអង្គមន្ត្រី ស្រុកត្រាំកក់ ខេត្តតាកែវ សម្រាប់ដាំបន្លែសរីរាង្គនេះ។

លោកអូលីវីយេ ជ្មីតហស្លេរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជាអ្នកផ្តួចផ្តើមគំនិតនេះ បានអញ្ជើញប្រារព្ធពិធីបាចទឹកព្រះពរលើដីសាងសង់រោងបន្លែជាមួយព្រះសង្ឃនៅក្នុងវត្តអង្គមន្ត្រី រួមនិងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទដែលជាគណៈកម្មការវត្តនិងព្រះសហគមន៍កាតូលិកមួយចំនួន។

លោកអភិបាលបានឱ្យដឹងថា កិច្ចការនេះជាសញ្ញានៃមិត្តភាព ការសហការណ៍គ្នា លើកទឹកចិត្តគ្នាទៅវិញទៅមករវាងសាសនាទាំងពីរ។

លោកអភិបាលមានប្រសាសន៍ទៀតថា៖ «ជិតដល់រដូវវស្សា ជាពេលវេលាមួយដ៏ល្អបំផុត ដើម្បីឱ្យយើងដឹងថា យើងមានបន្លែយ៉ាងខៀវខ្ចី ឆ្ងាញ់ ដែលជួយឱ្យយើងមានសុខភាពល្អនិងឱ្យយើងរួមគ្នានៅក្នុងសាសនាទាំងពីរការពារថែរក្សាសុខដុមរម្យនាដើម្បីកសាងប្រទេសជាតិរបស់យើង និងដើម្បីឈ្នះកូវីដ១៩នៅក្នុងគ្រប់កាលៈទេសៈ»។

លោក យុន សំអាត នាយកនៃវិទ្យាល័យចំណេះដឹងទូទៅនិងឯកទេសសន្តហ្វ្រង់ស្វ័រដែលជាសាលារបស់ព្រះសហគមន៍កាតូលិកបាននិយាយថា គោលដៅរបស់យើងមាន៣ធំៗ ទី១ សម្រាប់ជួយដោះស្រាយចង្ហាន់របស់ព្រះសង្ឃក្នុងវិបត្តិកូវីដ១៩ ទី២ ជួយដល់ប្រជាជនជុំវិញវត្តដែលមានជីវភាពខ្វះខាតអាចយកបន្លែទៅដោះស្រាយជីវភាពបានខ្លះ និងទី៣ ដើម្បីសុខដុមនីយកម្មសាសនានិងសាសនា។



លោកអូលីវីយេ ជ្មីតហស្លេរ បានអញ្ជើញប្រារព្ធពិធីបាចទឹកព្រះពរលើដីសាងសង់រោងបន្លែជាមួយព្រះសង្ឃនៅក្នុងវត្តអង្គមន្ត្រី រួមនិងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទ **ព្រះសហគមន៍កាតូលិក**

រោងបន្លែសរីរាង្គនេះមានទំហំ១០គុណនឹង១៥ម៉ែត្រ ដែលសង់ឡើងក្នុងដីវត្តអង្គមន្ត្រីនឹងដាំបន្លែសរីរាង្គគ្រប់មុខនៅលើដីដែលទទួលបច្ចេកទេសពីសាលាចំណេះដឹងទូទៅនិងឯកទេសសន្តហ្វ្រង់ស្វ័រដែលមានជំនាញខាងកសិកម្មស្រាប់៕

# ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ



សូមថ្វាយព្រះពរមហាប្រសើរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
នៅក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៨៤ ព្រះវស្សា យាងចូល៨៥ព្រះវស្សា។
ទូលព្រះបង្គំយើងខ្ញុំ ជាកូន ជាចៅ ជាចៅទួត សូមអង្វរព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
សូមព្រះអង្គប្រោសប្រទានព្រះពរ ជ័យ សិរីសួស្តី សុភមង្គល ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អ
និងព្រះប្រាជ្ញាញាណភ្លឺថ្លា ថ្វាយដល់ព្រះមហាក្សត្រី សម្តេចម៉ែ សម្តេចយាយ សម្តេចយាយទួត
ដើម្បីព្រះអង្គស្តេចទ្រង់គង់ប្រថាប់ជាមួយដ៏ត្រជាក់ត្រជុំថ្កុំថ្កើង និងសម្បូរសប្បាយ
ដល់ប្រជាជននិងមាតុភូមិកម្ពុជារៀងរហូត។
ក្រាបបង្គំទូលថ្វាយពី

CSC
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា
Catholic social communications cooperation dialogue

RADIO VERITAS ASIA
RVA KHMER